- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០២ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងកិច្ចការនារី
- បានឃើញអនុក្រឹត្យលេខ ១៣ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០០៥ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកិច្ចការនារី
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០១៥ ស្ដីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រង នៃក្រសួង ស្ថាប័នជាតិ និងថ្នាក់ក្រោមជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## សម្រេច

**មាត្រា ១ .-** សម្រួលភារកិច្ច លោកស្រី **ចាន់ សុធាទី** ពីអគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី មកជាអគ្គនាយករង នៃអគ្គនាយកដ្ឋានសមភាពយេនឌ័រ និងអភិវឌ្ឍន៍សេដ្ឋកិច្ច នៅក្រសួងកិច្ចការនារី ជំនួសលោកស្រី ជិន **ស៊ីវ៉េត** ដែលបានចូលនិវត្តន៍។

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងកិច្ចការនារី រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះ ហត្ថលេខាតទៅ។

ថ្ងៃ អង្គារ ៨ កើត ខែ ចេត្រ ឆ្នាំ ច សំរឹទ្ធិស័ក ព.ស ២៥៦២
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១៨

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:..៤៩៨...អនក្រ.បក

## អនុក្រឹត្យ

### ស្តីពី

### ការដាក់មន្ត្រីពន្ធនាគារឲ្យចូលនិវត្តន៍

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២១១/០២១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីពន្ធនាគារ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៣/៨៩២ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៣ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីពន្ធនាគារក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ៨០ អនក្រ.បក ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០២ ស្តីពីការគ្រប់គ្រងដំណើរការ នៃការដាក់មន្ត្រីរាជការស៊ីវិលឲ្យចូលនិវត្តន៍តាមអាយុ តាមប្រព័ន្ធព័ត៌មានវិទ្យា
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ .-**

ដាក់មន្ត្រីពន្ធនាគារចំនួន ០២រូប ឲ្យចូលនិវត្តន៍ក្នុងឋានន្តរស័ក្តិវរអគ្គានុរក្ស នៃក្របខ័ណ្ឌមន្ត្រីពន្ធនាគារក្រសួងមហាផ្ទៃ :

១- លោក **យ៉ង សុផល** អគ្គលេខ ០២៤៧ វរអគ្គានុរក្សថ្នាក់លេខ១

២- លោកស្រី **អោម ដន** អគ្គលេខ ០២១៩ វរអគ្គានុរក្សថ្នាក់លេខ១ ។

**មាត្រា ២** .-

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣** .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រី គ្រប់ក្រសួង ប្រធានស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗ ខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*ថ្ងៃ ៗ ឆ ៩ កើត ខែ ទុតិយាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២*

*រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ២០១៨*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**<u>កន្លែងទទួល</u>**

*-ក្រសួងព្រះបរមរាជវាំង*
*-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*
*-អគ្គលេខាធិការរាជរដ្ឋាភិបាល*
*-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
*-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
*-ដូចមាត្រា ៣*
*-រាជកិច្ច*
*-ឯកសារ កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ...៤៩៩....អនក្រ.តត

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ
## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១.** បំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ** ចំនួន ០៨ គ្រឿង ជូនសប្បុរសជន ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ចូលរួមចំណែកជួយកសាងសមិទ្ធផលនានាក្នុងវិស័យព្រះពុទ្ធសាសនា និង ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ក្នុងវត្តមួយចំនួន ស្ថិតនៅក្នុងស្រុកមុខកំពូល ខេត្តកណ្តាល ដូចមានរាយនាមខាងក្រោម៖

**ក-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទ**

១-ព្រះតេជគុណ **យ៉ស ស៊ីយាន** ព្រះចៅអធិការវត្តជោតនារាម

២-ព្រះតេជគុណ **សោម ផុន** ព្រះចៅអធិការវត្តសិរីជ័យមង្គល

៣-ព្រះតេជគុណ **ខួន ហ៊ើ** ព្រះចៅអធិការវត្តមនីរតនារាម

៤-ព្រះតេជគុណ **ផន សុភាព** ព្រះចៅអធិការវត្តជ្រៃមាសសាគរ

៥-ព្រះតេជគុណ **ឯម ជីសូ** ព្រះចៅអធិការវត្តបំពេញកុសល

៦-ព្រះតេជគុណ **យាន រតនៈ** ព្រះចៅអធិការវត្តសិរីមង្គលភូមិថ្មី

៧-ព្រះតេជគុណ **សឿន ថាវ័ន្ត** ព្រះចៅអធិការវត្តកែវមនីវ័ន

៨-ព្រះតេជគុណ **កែម បូរិទ្ធ** ព្រះចៅអធិការវត្តចតុមខារាម

**មាត្រា២.** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាលនៃគណៈអភិបាលខេត្តកណ្តាល និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃ ពុធ ៩ កើត ខែ ជេស្ឋ ឆ្នាំ ច សំរឹទ្ធិស័ក ព.ស. ២៥៦២
ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០១៨

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ...៥០០...អនក្រ.តត

# អនុក្រឹត្យ
## ស្ដីពីការជូនមេដាយស្ថាបនាជាតិ
## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្ដីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១.** បំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ចំនួន ១១ គ្រឿង ជូនសប្បុរសជន ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ចូលរួមចំណែកជួយកសាងសមិទ្ធផលនានាក្នុងវិស័យព្រះពុទ្ធសាសនា និង ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ក្នុងវត្តមួយចំនួន ស្ថិតនៅក្នុងស្រុកមុខកំពូល ខេត្តកណ្ដាល ដូចមានរាយនាមខាងក្រោម៖

**ក-មេដាយមាសស្ថាបនាជាតិ**

| | | | |
|---|---|---|---|
| ១-លោក | **សៅ សុធា** | សប្បុរសជន | បានឧបត្ថម្ភថវិកាចំនួន ១៧.៥០០ ដុល្លារ |
| ២-ឯកឧត្ដម | **អេង ឡួច** | សប្បុរសជន | បានឧបត្ថម្ភថវិកាចំនួន ១៤.០០០ ដុល្លារ |
| ៣-លោកស្រី | **ឃុន សុខេម** | សប្បុរសជន | បានឧបត្ថម្ភថវិកាចំនួន ១៣.០០០ ដុល្លារ |
| ៤-លោកស្រី | **សុខ ចាន់ធូ** | សប្បុរសជន | បានឧបត្ថម្ភថវិកាចំនួន ១១.០០០ ដុល្លារ |
| ៥-ឧបាសក | **ម៉ៅ ញ៉ូ** | សប្បុរសជន | បានឧបត្ថម្ភថវិកាចំនួន ១១.០០០ ដុល្លារ |
| ៦-ឧបាសិកា | **ឃួយ ដឹប** | សប្បុរសជន | បានឧបត្ថម្ភថវិកាចំនួន ១១.០០០ ដុល្លារ |

**ខ-មេដាយប្រាក់ស្ថាបនាជាតិ**

| | | | |
|---|---|---|---|
| ១-លោកស្រី | **តាំង ជាលន់** | សប្បុរសជន | បានឧបត្ថម្ភថវិកាចំនួន ៧.០០០ ដុល្លារ |
| ២-លោក | **អ៊ុក ពិសិដ្ឋ** | សប្បុរសជន | បានឧបត្ថម្ភថវិកាចំនួន ៥.៧០០ ដុល្លារ |
| ៣-ឧបាសក | **គ្រៀល ធឿន** | សប្បុរសជន | បានឧបត្ថម្ភថវិកាចំនួន ៥.៥០០ ដុល្លារ |
| ៤-លោក | **ប្រាក់ ណាល់** | សប្បុរសជន | បានឧបត្ថម្ភថវិកាចំនួន ៥.០០០ ដុល្លារ |
| ៥-ឧបាសិកា | **ជួន មឿន** | សប្បុរសជន | បានឧបត្ថម្ភថវិកាចំនួន ៥.០០០ ដុល្លារ |

**មាត្រា២.**_ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាលនៃគណៈអភិបាលខេត្តកណ្តាល និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ៩ កើត ខែ ជេស្ឋ ឆ្នាំ ច សំរឹទ្ធិស័ក ព.ស. ២៥៦២

ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០១៨

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៥០១ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពី
## ការតែងតាំងមុខតំណែងមន្ត្រីនគរបាលជាតិកម្ពុជា

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

### សម្រេច

**មាត្រា ១** ៖ ត្រូវបានផ្ទេរភារកិច្ច និងតែងតាំងមុខតំណែងលោកឧត្តមសេនីយ៍ទោ **ពេជ្រ មុនីរតន៍** អត្តលេខ ៥៥៤១៦ ពីអគ្គនាយករង នៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង ទៅជាអគ្គនាយករង នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ។

**មាត្រា ២** ៖ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដែលមានចែងក្នុងមាត្រា ១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃ ពុធ ៨ កើត ខែ ជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០១៨

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៥០៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការផ្ទេរក្របខ័ណ្ឌ នាយទាហាន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ ២០០១ ស្តីពីការកែសម្រួលតួនាទី ភារកិច្ចនិងរចនាសម្ព័ន្ធចាត់តាំង របស់អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ

## សម្រេច

**មាត្រា១ ៖** ផ្ទេរក្របខ័ណ្ឌ នាយទាហាន នៃកងយោធពលខេមរភូមិន្ទ ជូនឧត្តមសេនីយ៍ទោ **ឡុង ហាបាណា** អត្តលេខ ០០២៣៩១ មេបញ្ជាការរង កងពលតូចលេខ៧០ អគ្គបញ្ជាការដ្ឋាន បច្ចុប្បន្នទៅបម្រើការងារក្នុងក្របខ័ណ្ឌក្រសួងមហាផ្ទៃ ។

**មាត្រា២ ៖** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃ [illegible] ខែ [illegible] ឆ្នាំ ច សំរឹទ្ធិស័ក ព.ស ២៥៦២

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០១៨

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៥០៣ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពី
## ការផ្ទេរ និងតែងតាំងមុខតំណែងមន្ត្រីនគរបាលជាតិកម្ពុជា

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

### សម្រេច

**មាត្រា ១** ៖ ផ្ទេរ និងតែងតាំងមុខតំណែងនាយនគរបាលថ្នាក់ឧត្តមសេនីយ៍ ចំនួន ០២ រូប ដូចមានរាយនាមខាងក្រោម ៖

១- លោកឧត្តមសេនីយ៍ឯក **អ៊ុន ស៊ីណេន** អត្តលេខ ០៧១១ ពីអនុប្រធាននាយកដ្ឋានបុគ្គលិក ទៅជាទីប្រឹក្សា ក្រសួងមហាផ្ទៃ មានឋានៈស្មើ **អគ្គនាយករង** ។

២- លោកឧត្តមសេនីយ៍ត្រី **កៅ កេសរះ** អត្តលេខ ៣៩១០០ ពីនាយការិយាល័យគ្រប់គ្រងឯកសារ ទៅជាអនុប្រធាននាយកដ្ឋានបុគ្គលិក ដែលមានឋានៈ និងបុព្វសិទ្ធិស្មើ **ប្រធាននាយកដ្ឋាន** ។

**មាត្រា ២ ៖** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដែលមានចែងក្នុងមាត្រា ១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃ ពុធ ៩ កើត ខែ ជេស្ឋ ឆ្នាំច សំរឹទ្ធិ ព.ស ២៥៦២

ធ្វើនៅរាជធានីភ្នំពេញ.ថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០១៨

**នាយករដ្ឋមន្ត្រី**



**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥០៤ អនក្រ.តត

## អនុក្រឹត្យ
## ស្តីពី
## ការតែងតាំងមន្ត្រីរាជការ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការ រៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើត ក្រសួងសាធារណៈការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងសាធារណការ និងដឹងជញ្ជូន
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តី ពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រង នៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

### សម្រេច

**មាត្រា ១** : តែងតាំងលោក **អេង កុសល្យ** ជាអធិការ នៃអគ្គាធិការ ក្រសួងសាធារណការ និងដឹកជញ្ជូន ។

**មាត្រា ២** : បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ ត្រូវទទួលបន្ទុក អនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃច័ន្ទ ១៤កើត ខែពិសាខ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២
ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែឧសភា ឆ្នាំ ២០១៨

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល** :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ៥.៧៥.អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការតម្លើងឋានន្តរស័ក្តិមន្ត្រីនគរបាលជាតិកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១** ៖ តម្លើងឋានន្តរស័ក្តិ **វរសេនីយ៍ឯក** ដល់នាយនគរបាលជាន់ខ្ពស់ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ៖

១- វរសេនីយ៍ទោ **ម៉ែន សារ៉ូត** អត្តលេខ ០៥០២៧
២- វរសេនីយ៍ទោ **យន សុធា** អត្តលេខ ០៦០៦៣
៣- វរសេនីយ៍ទោ **សំ ម៉ូឆន** អត្តលេខ ០៦២០០
៤- វរសេនីយ៍ទោ **ម៉ឹង បូរិន** អត្តលេខ ៣៣២៨៤

៥- វរសេនីយ៍ទោ **ថូ ម៉ុនធឿន** អត្តលេខ ៣៩២៣៣

៦- វរសេនីយ៍ទោ **ទ៉ា សំអោក** អត្តលេខ ៣៩២៤៤ ។

**មាត្រា ២** ៖ រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដែលមានចែងក្នុងមាត្រា ១ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*ថ្ងៃព្រហស្បតិ៍ ១០កើត ខែផល្គុន ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២*
*ធ្វើនៅរាជធានីភ្នំពេញ.ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០១៨*

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**អន្លែងទទួល**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ:** ៥០៦.អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការដាក់ឲ្យចូលនិវត្តន៍មន្ត្រីនគរបាលជាតិកម្ពុជា

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត/ ០៩១៣ / ៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញក្រឹត្យលេខ ១០ក្រ ចុះថ្ងៃទី ០៨ ខែកម្ភៈ ឆ្នាំ១៩៩៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីរបបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពពលកម្មចំពោះនគរបាលប្រជាជនកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៥០១ / ១៧៨ ចុះថ្ងៃទី ២២ ខែឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៦១០ / ៤៦៤ ចុះថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ២០១០ ស្តីពីការកែសម្រួលមាត្រា៣៥ នៃព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ស ម្រេ ច

**មាត្រា ១** : ដាក់ឲ្យចូលនិវត្តន៍នាយនគរបាលជាន់ខ្ពស់ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ចំនួន ០៣ រូប ដូចមានរាយនាមខាងក្រោម ៖

| | | | | |
|---|---|---|---|---|
| ១ | វរសេនីយ៍ឯក | **ស ខេមរា** | អត្តលេខ | ០១៧២ |
| ២ | វរសេនីយ៍ឯក | **ឡុង ណាតី** | អត្តលេខ | ០២២១៤ |
| ៣ | វរសេនីយ៍ឯក | **ឃិន ទុទ្ធា** | អត្តលេខ | ១៥៦៣៨ ។ |

**មាត្រា ២** : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃព្រហស្បតិ៍ ១០កើត ខែជេស្ឋ ឆ្នាំ ច សំរឹទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៨

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

*កន្លែងទទួល:*

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាលកម្ពុជា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខៈ៥០៧ អនុក្រ.តត**

# អនុក្រឹត្យ
## ស្តីពី
## ការដំឡើងឋានន្តរស័ក្តិ នាយទាហាន

# រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ ២០០១ ស្តីពីការកែសម្រួលតួនាទី ភារកិច្ចនិងរចនាសម្ព័ន្ធចាត់តាំង របស់អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ

## សម្រេច

**មាត្រា១ :** ដំឡើងឋានន្តរស័ក្តិ ថ្នាក់វរសេនីយ៍ឯក នាយទាហាន នៃកងយោធពលខេមរភូមិន្ទ ជាសិក្ខាកាម បញ្ចប់វគ្គសិក្សាក្នុងនិងក្រៅប្រទេស ដែលមានរាយនាមដូចខាងក្រោមៈ

១-វរសេនីយ៍ទោ **រស់ ទិចិត្រ** អត្តលេខ ០៥៨១៥៧ សិក្ខាកាម វគ្គបណ្តុះបណ្តាលយុទ្ធសាស្ត្រការពារជាតិ មហាវិទ្យាល័យការពារជាតិ សាធារណរដ្ឋឥណ្ឌូនេស៊ី

២-វរសេនីយ៍ទោ **អ៊ីន ម៉ិនថន** អត្តលេខ ២២៧៩២៨ សិក្ខាកាម វគ្គបណ្តុះបណ្តាលបញ្ជាការសេនាធិការ កងទ័ពជើងគោក សាកលវិទ្យាល័យយោធាចម្រុះ ប្រទេសអូស្ត្រាលី

៣-វរសេនីយ៍ទោ **ម៉ុន ធីលីណា** អត្តលេខ ០៦៧៧២២ សិក្ខាកាម វគ្គបណ្តុះបណ្តាលភាសាអង់គ្លេសកម្រិតខ្ពស់ មជ្ឈមណ្ឌលហ្វឹកហ្វឺនអន្តរជាតិ ការពារជាតិ ប្រទេសអូស្ត្រាលី

៤-វរសេនីយ៍ទោ **ខួន ទិមុល** អត្តលេខ ២៣០០៦៧ សិក្ខាកាម វគ្គបណ្តុះបណ្តាលភាសាអង់គ្លេសកម្រិតខ្ពស់ មជ្ឈមណ្ឌលហ្វឹកហ្វឺនអន្តរជាតិ ការពារជាតិ ប្រទេសអូស្ត្រាលី

៥-វរសេនីយ៍ទោ **សាន ព្រហស្ស៍ត្រា** (នារី) អត្តលេខ ១៦៣២៤៩ សិក្ខាកាម វគ្គបណ្តុះបណ្តាលភាសាអង់គ្លេសកម្រិតខ្ពស់ មជ្ឈមណ្ឌលហ្វឹកហ្វឺនអន្តរជាតិ ការពារជាតិ ប្រទេសអូស្ត្រាលី

៦-វរសេនីយ៍ទោ **ឡេីន សុធី** អត្តលេខ ១៦៤៣៩១ សិក្ខាកាម វគ្គបណ្តុះបណ្តាលការពារជាតិ ជំនាន់ទី១១ សាកលវិទ្យាល័យការពារជាតិ

៧-វរសេនីយ៍ទោ **សេម សុផាណា** អត្តលេខ ០៤៦៧៤៣ សិក្ខាកាម វគ្គបណ្តុះបណ្តាលបញ្ជាការសេនាធិការ សាកលវិទ្យាល័យការពារជាតិ

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃព្រហស្បតិ៍ ១០កើត ខែជេស្ឋ ឆ្នាំ ច សំរឹទ្ធិស័ក ព.ស ២៥៦២
ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០១៨

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ៥០៨.អនក្រ.តត

## អនុក្រឹត្យ
## ស្តីពី
## ការតែងតាំង និងប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ២៨៣ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ៦៣ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រងការអនុវត្តន៍ការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់របស់មន្ត្រីរាជការស៊ីវិល
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០១៥ ស្តីពីការកំណត់របនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## សម្រេច

**មាត្រា ១.-** តែងតាំង និងប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ចំនួន ០២ រូប នៅវិទ្យាស្ថានពហុបច្ចេកទេសព្រះកុសមៈ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដូចមានរាយនាមខាងក្រោម ៖

១- លោក **ឃ្លោក ហ៊ីម៉ានី** ប្រគល់ភារកិច្ចឱ្យបំពេញមុខងារជា នាយករង នៃវិទ្យាស្ថានពហុបច្ចេកទេសព្រះកុសមៈ មានឋានៈស្មើអគ្គនាយករង ជំនួសលោក **តាំង យឿន** ដែលបានទទួលភារកិច្ចថ្មី។

២- លោក **អ៊ិន សារធួន** ជាព្រឹទ្ធបុរសមហាវិទ្យាល័យសំណង់ មានឋានៈស្មើប្រធាននាយកដ្ឋាន ជំនួសលោក **ឃ្លោក ហ៊ីម៉ានី** ដែលបានទទួលភារកិច្ចថ្មី។

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ព្រហស្បតិ៍ ១០ កើត ខែជេស្ឋ ឆ្នាំ ច សំរឹទ្ធិស័ក ព.ស ២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០១៨

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ៥០៩.អនក្រ.តត

# អនុក្រឹត្យ
## ស្តីពី
## ការតែងតាំងមុខងារ នាយទាហាន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ ២០០១ ស្តីពីការកែសម្រួលតួនាទី ភារកិច្ចនិងរចនាសម្ព័ន្ធចាត់តាំង របស់អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ

### សម្រេច

**មាត្រា១ៈ** តែងតាំងមុខងារ នាយទាហាន នៃកងយោធពលខេមរភូមិន្ទ ដែលមានរាយនាមដូចខាងក្រោមៈ

១-ឧត្តមសេនីយ៍ទោ **មៀច សាមុត** អត្តលេខ ០១៨៣៨៥ ជា មេបញ្ជាការរង យោធភូមិភាគទី១ និងជា មេបញ្ជាការ កងពលតូចអន្តរាគមន៍លេខ១២៨

២-ឧត្តមសេនីយ៍ទោ **អ៊ុន ស៊ីដារ៉ា** អត្តលេខ ០០០១៤៧ ជា មេបញ្ជាការរង យោធភូមិភាគទី២ និងជា មេបញ្ជាការ កងពលតូចថ្មើរជើងលេខ២១

៣-ឧត្តមសេនីយ៍ទោ **នាង ឃីម** អត្តលេខ ០០១១៥៩ ជា មេបញ្ជាការរង យោធភូមិភាគទី៤ និងជា មេបញ្ជាការ កងពលតូចថ្មើរជើងលេខ៤១

៤-ឧត្តមសេនីយ៍ទោ **ម៉ែន ឌុំយ** អត្តលេខ ០០៣៨១២ ជា មេបញ្ជាការរង យោធភូមិភាគទី៤ និងជា មេបញ្ជាការ កងពលតូចថ្មើរជើងលេខ៤២

៥-ឧត្តមសេនីយ៍ទោ **មុី សីទ្ធាន** អត្តលេខ ០០០៤២៦ ជា មេបញ្ជាការរង យោធភូមិភាគទី៥ និងជា មេបញ្ជាការ កងពលតូចថ្មើរជើងលេខ៥២

៦-ឧត្តមសេនីយ៍ទោ **ជា** **ឡុងគិរម្យ** អត្តលេខ ០០៣៨១៧ ជា មេបញ្ជាការរង យោធភូមិភាគទី៥ និងជា មេបញ្ជាការ កងពលតូចថ្មើរជើងលេខ៥៣

៧-ឧត្តមសេនីយ៍ទោ **ជា** **សុទ្ធី** អត្តលេខ ០២២៣១៧ ជា សាកលវិទ្យាធិការរង សាកលវិទ្យាល័យការពារជាតិ

៨-ឧត្តមសេនីយ៍ទោ **ជេត** **សារ៉ុន** អត្តលេខ ០០៣២៤៣ ជា សាកលវិទ្យាធិការរង សាកលវិទ្យាល័យការពារជាតិ

៩-ឧត្តមសេនីយ៍ទោ **ស៊ិន** **សាម៉ៀន** អត្តលេខ ០០៩៣៩៥ ជា អគ្គលេខាធិការរង ក្រសួងការពារជាតិ

១០-ឧត្តមសេនីយ៍ទោ **ង៉ោ** **ស្រ៊ុន** អត្តលេខ ០២០០៦៨ ជា អគ្គលេខាធិការរង ក្រសួងការពារជាតិ

១១-ឧត្តមសេនីយ៍ត្រី **អ៊ុំ** **ចន្ថា** អត្តលេខ ០១៦៣៩៩ ជា មេបញ្ជាការរង យោធភូមិភាគទី៥

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គ-មេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធនិងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃ ព្រហស្បតិ៍ ១០ កើត ខែ ជេស្ឋ ឆ្នាំ ច សំរឹទ្ធិស័ក ព.ស ២៥៦២
ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០១៨

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ [illegible] សហវ.[illegible]

# ប្រកាស
## ស្តីពី
## ការរៀបចំនិងការប្រព្រឹត្តទៅនៃនាយកដ្ឋាននិងអង្គភាព ក្រោមឱវាទរបស់អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី៣ ខែមីនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមាត្រា៤៤ មាត្រា៤៥ និងមាត្រា៤៧ នៃអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញអនុក្រឹត្យលេខ ៩៥ អនក្រ.បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការដំឡើងវិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ១១៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៦ ស្តីពីការតម្លើងនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍, តម្លើងនាយកដ្ឋានសហប្រតិបត្តិការ និងគ្រប់គ្រងបំណុល ទៅជា អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល និងបង្កើតនាយកដ្ឋានសវនកម្មបច្ចេកវិទ្យា ព័ត៌មាន ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួល អនុក្រឹត្យលេខ ៤៨៨ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

### ជំពូកទី១
### បទប្បញ្ញត្តិទូទៅ

**ប្រការ១.-**

ប្រកាសនេះ មានគោលដៅកំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅនៃនាយកដ្ឋាន និងអង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ២.-**

ប្រកាសនេះមានគោលបំណងដូចខាងក្រោម÷

- រៀបចំបេសកកម្ម និងរចនាសម្ព័ន្ធរបស់នាយកដ្ឋាន និងអង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ
- រៀបចំតួនាទី និងភារកិច្ចរបស់នាយកដ្ឋាន និងអង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ
- ធានាគុណភាព និងប្រសិទ្ធភាពនៃលទ្ធផលបំពេញការងារ ក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ។

**ប្រការ៣.-**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះគ្រប់នាយកដ្ឋាន និងអង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ។

## ជំពូកទី២
## បេសកកម្មនិងរចនាសម្ព័ន្ធ

**ប្រការ៤.-**

អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ បំពេញមុខងារជាសេនាធិការឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើបេសកកម្មគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ។

**ប្រការ៥.-**

អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ មានភារកិច្ច ដូចតទៅ÷

- រៀបចំសេចក្តីព្រាងច្បាប់ គោលនយោបាយ យុទ្ធសាស្ត្រ និងលិខិតបទដ្ឋាននានា ទាក់ទងនឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ
- គ្រប់គ្រងនិងជំរុញការធ្វើបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរបស់រដ្ឋ នៅទូទាំងប្រទេស
- ស្រាវជ្រាវនិងគ្រប់គ្រងទ្រព្យឥតម្ចាស់ និងមរតកឥតបណ្តឹង
- គ្រប់គ្រងការប្រមូលចំណូលមិនមែនសារពើពន្ធ
- គ្រប់គ្រងភាគហ៊ុនរបស់រដ្ឋនិងដើមទុនរបស់រដ្ឋ
- គ្រប់គ្រងសហគ្រាសសាធារណៈ អង្គភាពសាធារណៈ និងអង្គភាពរដ្ឋដទៃទៀត
- ប្រមូលផ្តុំព័ត៌មានពាក់ព័ន្ធការងារឯកជនភាវូបនីយកម្ម ការជម្រះបញ្ជីសហគ្រាសសាធារណៈ និងអង្គភាពរដ្ឋដទៃទៀត
- គ្រប់គ្រងនិងរៀបចំបញ្ជីសម្បទានដីសេដ្ឋកិច្ច សម្បទានព្រៃឈើ សម្បទានរ៉ែ និងសម្បទានដទៃទៀតដែលបានផ្តល់ឱ្យវិស័យឯកជន
- រៀបចំនីតិវិធីវាយតំលៃការដាក់ជួល លក់ ដូរ និងផ្ទេរសិទ្ធិទ្រព្យសម្បត្តិរដ្ឋ
- គ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ និងការរៀបចំផែនការប្រមូលចំណូល និងបំណុលមិនមែនសារពើពន្ធមានលក្ខណៈប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន
- រៀបចំយុទ្ធសាស្ត្រគ្រប់គ្រងកិច្ចដំណើរការប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានលើការងារប្រមូលចំណូលមិនមែនសារពើពន្ធនិង គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ
- រក្សាការពារទិន្នន័យនៃការគ្រប់គ្រងការប្រមូលចំណូល និងបំណុលមិនមែនសារពើពន្ធ និងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋនៅក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន
- ស្រាវជ្រាវរកប្រភពចំណូលមិនមែនសារពើពន្ធផ្សេងៗទៀត
- ចូលរួមរៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុ។

**ប្រការ៦.-**

អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ មាននាយកដ្ឋានក្រោមឱវាទចំនួន ៥ និងលេខាធិការដ្ឋាន ១ ដូចខាងក្រោម÷

- នាយកដ្ឋានសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ
- នាយកដ្ឋានចំណូលពីទ្រព្យសម្បត្តិរដ្ឋ
- នាយកដ្ឋានចំណូលសាធារណៈ
- នាយកដ្ឋានសហគ្រាសសាធារណៈ
- នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន
- លេខាធិការដ្ឋាន

នាយកដ្ឋាននីមួយៗមានការិយាល័យចំណុះមួយចំនួន តាមការចាំបាច់។

អង្គការលេខនៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ ត្រូវបានកំណត់នៅក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ៧.-**

- នាយកដ្ឋាននីមួយៗ នៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ ដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួនជាជំនួយការ
- លេខាធិការដ្ឋាន នៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ ដឹកនាំដោយប្រធានមួយរូប មានឋានៈស្មើអនុប្រធាននាយកដ្ឋាន និងអមដោយអនុប្រធានមួយចំនួនជាជំនួយការ មានឋានៈស្មើប្រធានការិយាល័យ
- ការិយាល័យចំណុះនាយកដ្ឋាននីមួយៗនៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធដឹកនាំដោយប្រធានមួយរូប និងអមដោយអនុប្រធានមួយចំនួនជាជំនួយការ។

## ជំពូកទី៣
## នាយកដ្ឋានសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ

**ប្រការ៨.-**

តួនាទី និងភារកិច្ចរបស់នាយកដ្ឋានសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ នៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ មានដូចខាងក្រោម÷

- បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ លើការងារគ្រប់គ្រងបញ្ជីសារពើភណ្ឌ
- រៀបចំសេចក្តីព្រាងច្បាប់ គោលនយោបាយ យុទ្ធសាស្ត្រ និងលិខិតបទដ្ឋាននានា ទាក់ទងនឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងផ្សព្វផ្សាយនីតិវិធីថ្មីៗ ដែលដាក់ចេញក្នុងការជំរុញ ការកែលំអ និងការកែសម្រួលនៃការរៀបចំ និងការគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ
- គ្រប់គ្រង និងជម្រះបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ព្រមទាំងតម្កល់កិច្ចសន្យា កិច្ចព្រមព្រៀង សៀវភៅបន្ទុក ពីការជួល វិនិយោគ សម្បទាន និងការធ្វើឯកជនភាវូបនីយកម្មទ្រព្យសម្បត្តិរដ្ឋ

- គ្រប់គ្រងការងារប្រទានកម្មទ្រព្យសម្បត្តិរបស់រដ្ឋ
- ចូលរួមរៀបចំគម្រោងថវិកាប្រចាំឆ្នាំ ក្នុងដំណើរការរៀបចំសេចក្ដីព្រាងច្បាប់ ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងនៃឆ្នាំនីមួយៗ។

**ប្រការ៩.-**

នាយកដ្ឋានសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ មានការិយាល័យក្រោមឱវាទចំនួនបី ដូចខាងក្រោម÷

- ការិយាល័យសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋថ្នាក់ជាតិ
- ការិយាល័យសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋថ្នាក់ក្រោមជាតិ
- ការិយាល័យសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋថ្នាក់នីតិបុគ្គលសាធារណៈ។

**ប្រការ១០.-**

តួនាទី និងភារកិច្ចរបស់ការិយាល័យសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋថ្នាក់ជាតិ មានដូចខាងក្រោម÷

- ចូលរួមផ្ដួចផ្ដើម និងរៀបចំលិខិតបទដ្ឋានគតិយុត្ត សម្រាប់ការគ្រប់គ្រងសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋថ្នាក់ជាតិ
- គ្រប់គ្រង តម្កល់ និងជម្រះបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ដែលកាន់កាប់ដោយក្រសួងស្ថាប័ន និងអង្គភាពក្រោមឱវាទក្រសួង ស្ថាប័នទាំងនោះ
- ផ្ដួចផ្ដើម រៀបចំ និងកែលំអការទុកដាក់តម្កល់ឯកសារបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋទាំងអស់នៅទូទាំងប្រទេស រួមទាំងបញ្ជីជួល លក់ ដូរទ្រព្យសម្បត្តិរដ្ឋ បញ្ជីសម្បទានដីសេដ្ឋកិច្ច បញ្ជីសម្បទានព្រៃឈើ បញ្ជីសម្បទានរ៉ែ និងសម្បទានទ្រព្យសម្បត្តិរដ្ឋដទៃទៀត
- គ្រប់គ្រងការងារផ្ទេរ និងប្រទានកម្មទ្រព្យសម្បត្តិរដ្ឋថ្នាក់ជាតិ
- ចូលរួមពិធីប្រគល់ទទួលទ្រព្យសម្បត្តិរដ្ឋ ដែលកាន់កាប់ដោយក្រសួង ស្ថាប័ន និងអង្គភាពក្រោមឱវាទក្រសួងស្ថាប័នទាំងនោះ
- ផ្សព្វផ្សាយនីតិវិធីផ្សេងៗ ពិនិត្យតាមដាន និងផ្ទៀងផ្ទាត់ជាប្រចាំ ដើម្បីបច្ចុប្បន្នភាពបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋដែលកាន់កាប់ដោយក្រសួង ស្ថាប័ន និងអង្គភាពក្រោមឱវាទក្រសួង ស្ថាប័នទាំងនោះ
- ផ្សព្វផ្សាយនីតិវិធីថ្មីៗ ដែលដាក់ចេញក្នុងការជំរុញ ការកែលម្អ និងការកែសម្រួល ការរៀបចំ និងគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ
- កសាងផែនការចំណូល និងបំណុលប្រចាំឆ្នាំពីការជម្រះបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋទាំងអស់
- ធ្វើរបាយការណ៍ទៀងទាត់ស្ដីពីសកម្មភាពការងាររបស់ការិយាល័យសាមី។

**ប្រការ១១.-**

តួនាទី និងភារកិច្ចរបស់ការិយាល័យសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋថ្នាក់ក្រោមជាតិ មានដូចខាងក្រោម÷

- ចូលរួមផ្ដួចផ្ដើមនិងរៀបចំលិខិតបទដ្ឋានគតិយុត្តសម្រាប់ការគ្រប់គ្រងសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋថ្នាក់ក្រោមជាតិ
- គ្រប់គ្រង តម្កល់ និងជម្រះបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់មន្ទីរ ឬអង្គភាព នៃក្រសួង ស្ថាប័ននៅថ្នាក់រាជធានីខេត្ត

- គ្រប់គ្រងការងារផ្ទេរ និងប្រទានកម្មទ្រព្យសម្បត្តិរដ្ឋ របស់មន្ទីរ ឬអង្គភាព នៃក្រសួង ស្ថាប័ននៅថ្នាក់រាជធានី ខេត្ត
- ចូលរួមពិធីប្រគល់ទទួលទ្រព្យសម្បត្តិរដ្ឋ ដែលកាន់កាប់ដោយមន្ទីរ ឬអង្គភាព នៃក្រសួង ស្ថាប័ននៅថ្នាក់រាជធានី ខេត្ត
- ពិនិត្យ តាមដាន និងផ្ទៀងផ្ទាត់ជាប្រចាំនូវបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ដែលកាន់កាប់ដោយមន្ទីរ ឬអង្គភាពនៃក្រសួង ស្ថាប័ននៅថ្នាក់រាជធានី ខេត្ត
- ធ្វើរបាយការណ៍ទៀងទាត់ស្តីពីសកម្មភាពការងាររបស់ការិយាល័យសាមី។

**ប្រការ១២.-**

តួនាទី និងភារកិច្ចរបស់ការិយាល័យសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋថ្នាក់នីតិបុគ្គលសាធារណៈ មានដូចខាងក្រោម÷

- ចូលរួមផ្តួចផ្តើម និងរៀបចំលិខិតបទដ្ឋានគតិយុត្តសម្រាប់ការគ្រប់គ្រងសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋថ្នាក់នីតិបុគ្គលសាធារណៈ
- គ្រប់គ្រង តម្កល់ និងជម្រះបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល និងនីតិបុគ្គលសាធារណៈដទៃទៀត
- គ្រប់គ្រងការងារផ្ទេរ និងប្រទានកម្មទ្រព្យសម្បត្តិរដ្ឋ របស់សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល និងនីតិបុគ្គសាធារណៈដទៃទៀត
- ពិនិត្យតាមដាន និងផ្ទៀងផ្ទាត់ជាប្រចាំ នូវបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ របស់សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល និងនីតិបុគ្គសាធារណៈដទៃទៀត
- ចូលរួមពិធីប្រគល់ទទួលទ្រព្យសម្បត្តិរដ្ឋ របស់សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល និងនីតិ-បុគ្គលសាធារណៈដទៃទៀត
- ធ្វើរបាយការណ៍ទៀងទាត់ស្តីពីសកម្មភាពការងាររបស់ការិយាល័យសាមី។

## ជំពូកទី៤
## នាយកដ្ឋានចំណូលពីទ្រព្យសម្បត្តិរដ្ឋ

**ប្រការ១៣.-**

តួនាទី និងភារកិច្ចរបស់នាយកដ្ឋានចំណូលពីទ្រព្យសម្បត្តិរដ្ឋនៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ មានដូចខាងក្រោម÷

- បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ លើការងារគ្រប់គ្រងចំណូលពីទ្រព្យសម្បត្តិរដ្ឋ ដោយផ្អែកលើមូលដ្ឋានច្បាប់ និងលិខិតបទដ្ឋានពាក់ព័ន្ធ
- ផ្តួចផ្តើម និងចូលរួមរៀបចំសេចក្តីព្រាងច្បាប់ គោលនយោបាយ យុទ្ធសាស្ត្រ និងលិខិតបទដ្ឋាននានាទាក់ទងនឹងការគ្រប់គ្រងចំណូលពីទ្រព្យសម្បត្តិរដ្ឋ
- គ្រប់គ្រងការងារឯកជនភាវូបនីយកម្មទ្រព្យសម្បត្តិរបស់រដ្ឋ ផ្អែកតាមការសម្រេចរបស់រាជរដ្ឋាភិបាល

- គ្រប់គ្រងចំណូល និងតាមដានការអនុវត្តកិច្ចសន្យា សៀវភៅបន្ទុក ពីការជួល វិនិយោគ សម្បទាន (ក្រៅពីសម្បទានរ៉ែ) និងការធ្វើឯកជនភាវូបនីយកម្មទ្រព្យសម្បត្តិរបស់រដ្ឋ
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ស្តីពីស្ថានភាពនៃការអនុវត្តចំណូល និងស្ថានភាពបំណុល
- ចូលរួមរៀបចំគម្រោងថវិកាប្រចាំឆ្នាំក្នុងដំណើរការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងនៃឆ្នាំនីមួយៗ។

**ប្រការ១៤.-**

នាយកដ្ឋានចំណូលពីទ្រព្យសម្បត្តិរដ្ឋ មានការិយាល័យក្រោមឱវាទចំនួនបី ដូចខាងក្រោម÷

- ការិយាល័យចំណូលទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ
- ការិយាល័យចំណូលសម្បទានទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ
- ការិយាល័យធនធានធម្មជាតិ។

**ប្រការ១៥.-**

តួនាទី និងភារកិច្ចរបស់ការិយាល័យចំណូលឯកជនរបស់រដ្ឋ មានដូចខាងក្រោម÷

- ចូលរួមផ្តួចផ្តើម និងរៀបចំលិខិតបទដ្ឋានគតិយុត្ត សម្រាប់ការគ្រប់គ្រងចំណូលទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ
- កសាងផែនការចំណូល និងបំណុលប្រចាំឆ្នាំពីការលក់-ជួល សហគ្រាស រោងចក្រ ចលនវត្ថុនិងអចលនវត្ថុ និងប្រាក់លម្អៀងពីការដូរទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ
- គ្រប់គ្រង និងពិនិត្យការងារនៃការលក់ ជួល ដូរ ផ្ទេរ ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ
- ពិនិត្យ កែសម្រួលកិច្ចសន្យា និងតាមដានការអនុវត្តកិច្ចសន្យាលក់ ជួល ដូរ ចលនវត្ថុនិងអចលនវត្ថុ ដែលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ
- តាមដាន និងជំរុញការប្រមូលចំណូលនិងបំណុលពីការលក់ ដូរ និងជួលសគ្រាស រោងចក្រ ចលនវត្ថុ និងអចលនវត្ថុ ដែលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋស្ថិតនៅក្រោមការកាន់កាប់របស់ក្រសួង ស្ថាប័ន និងរាជធានី ខេត្ត
- រៀបចំគម្រោងចំណូលទ្រព្យសម្បត្តិរបស់រដ្ឋដែលជាគម្រោងថវិកាប្រចាំឆ្នាំ ដើម្បីបញ្ចូលទៅក្នុងសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំនីមួយៗ
- ធ្វើរបាយការណ៍សរុបស្តីពីសកម្មភាពការងាររបស់ការិយាល័យសាមី។

**ប្រការ១៦.-**

តួនាទី និងភារកិច្ចរបស់ការិយាល័យចំណូលសម្បទានទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ មានដូចខាងក្រោម÷

- ចូលរួមផ្តួចផ្តើម និងរៀបចំលិខិតបទដ្ឋានគតិយុត្ត សម្រាប់ការគ្រប់គ្រងចំណូលទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ
- ស្រាវជ្រាវរកប្រភពចំណូលថ្មីៗនៃចំណូលសម្បទានទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ រួមមាន ជលផល ភាស៊ីផ្សារ កំពង់ចម្លង ចំណត សត្តឃាតដ្ឋាន អនាម័យសត្វ សេវាប្រមូលសំរាម និងចំណូលពីសម្បទានទ្រព្យសម្បត្តិ សាធារណៈរបស់រដ្ឋដទៃទៀត



។ ៤

- រៀបចំនីតិវិធីសម្រាប់ប្រមូលចំណូលពីសម្បទានទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ
- តាមដានការអនុវត្តកិច្ចសន្យា ឬសៀវភៅបន្ទុកនានា ដែលទាក់ទងនឹងប្រភេទចំណូលពីសម្បទានទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ
- ចូលរួមសម្របសម្រួល និងដោះស្រាយបញ្ហាដែលកើតឡើងជុំវិញការអនុវត្តកិច្ចសន្យាចំណូលពីសម្បទានទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ
- គ្រប់គ្រងកិច្ចសន្យានិងបញ្ជីសារពើភណ្ឌនៃទីតាំងផ្សារ កំពង់ចម្លង សត្តឃាតដ្ឋាន ទីតាំងដាក់សំរាមដែលជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ
- រៀបចំគម្រោងចំណូលពីសម្បទានទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ដែលជាគម្រោងថវិកាប្រចាំឆ្នាំ ដើម្បីបញ្ចូលទៅក្នុងសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំនីមួយៗ
- ធ្វើរបាយការណ៍សរុបស្តីពីសកម្មភាពការងាររបស់ការិយាល័យសាមី។

**ប្រការ១៧.-**

តួនាទី និងភារកិច្ចរបស់ការិយាល័យចំណូលធនធានធម្មជាតិ មានដូចខាងក្រោម÷

- ចូលរួមផ្តួចផ្តើម និងរៀបចំលិខិតបទដ្ឋានគតិយុត្ត សម្រាប់ការគ្រប់គ្រងចំណូលធនធានធម្មជាតិ
- គ្រប់គ្រង និងជំរុញការរៀបចំបញ្ជីសារពើភណ្ឌសម្បទានដីសេដ្ឋកិច្ច ព្រៃឈើ នៅទូទាំងប្រទេស
- គ្រប់គ្រងចំណូលប្រចាំឆ្នាំពីធនធានធម្មជាតិ សម្បទាន ដីសេដ្ឋកិច្ច និងគម្រោងសម្បទានដទៃទៀតក្រៅពីសម្បទានរ៉ែ
- តាមដាន និងជំរុញការប្រមូលចំណូល ប្រាក់កក់ និងបំណុលពីព្រៃឈើ សម្បទានដីសេដ្ឋកិច្ច និងពីធនធាន ធម្មជាតិដទៃទៀត
- ពិនិត្យ កែសម្រួលនិងតាមដានការអនុវត្តកិច្ចសន្យានានាពាក់ព័ន្ធនឹងសម្បទានដីសេដ្ឋកិច្ចព្រៃឈើ និងពីធនធានធម្មជាតិដទៃទៀត
- រៀបចំនិងពិនិត្យផ្តល់យោបល់លើឯកសារស្នើសុំពាក់ព័ន្ធនឹងសម្បទានដីសេដ្ឋកិច្ច ព្រៃឈើ និងពីធនធានធម្មជាតិដទៃទៀត
- រៀបចំគម្រោងចំណូលពីសម្បទានដីសេដ្ឋកិច្ច ព្រៃឈើ និងពីធនធានធម្មជាតិដទៃទៀត ដែលជាគម្រោងថវិកាប្រចាំឆ្នាំ ដើម្បីបញ្ចូលទៅក្នុងសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំនីមួយៗ
- ធ្វើរបាយការណ៍សរុបស្តីពីសកម្មភាពការងាររបស់ការិយាល័យសាមី។

## ជំពូកទី៥
## នាយកដ្ឋានចំណូលសាធារណៈ

**ប្រការ១៨.-**

តួនាទី និងភារកិច្ចរបស់នាយកដ្ឋានចំណូលសាធារណៈ នៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ មានដូចខាងក្រោម÷

- បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ លើការងារគ្រប់គ្រងចំណូលសាធារណៈ
- ផ្តួចផ្តើម និងចូលរួមរៀបចំសេចក្តីព្រាងច្បាប់ គោលនយោបាយ យុទ្ធសាស្ត្រ និងលិខិតបទដ្ឋាននានាទាក់ទងនឹងការគ្រប់គ្រងចំណូលសាធារណៈ និងសេវារដ្ឋបាលរបស់រដ្ឋ
- សិក្សារកប្រភពចំណូលសាធារណៈដទៃទៀត ព្រមទាំងគ្រប់គ្រងការងារផ្តល់រង្វាន់លើកទឹកចិត្ត លើការងារខិតខំប្រមូលចំណូលសាធារណៈ
- ចូលរួមដោះស្រាយទំនាស់វិវាទ លើការអនុវត្តចំណូលសាធារណៈ តាមផ្លូវច្បាប់ និងតុលាការ
- គ្រប់គ្រងចំណូល និងបូកសរុបប្រចាំខែ ស្តីពីស្ថានភាពអនុវត្តចំណូលសាធារណៈ និងសេវារដ្ឋបាលរបស់រដ្ឋ
- ចូលរួមរៀបចំគម្រោងថវិកាប្រចាំឆ្នាំ ក្នុងដំណើរការរៀបចំសេចក្តីព្រាងច្បាប់ ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងនៃឆ្នាំនីមួយៗ។

**ប្រការ១៩.-**

នាយកដ្ឋានចំណូលសាធារណៈ មានការិយាល័យក្រោមឱវាទចំនួនបួន ដូចខាងក្រោម÷

- ការិយាល័យចំណូលសាធារណៈវិស័យរដ្ឋបាលទូទៅ
- ការិយាល័យចំណូលសាធារណៈវិស័យការពារជាតិនិងសន្តិសុខ
- ការិយាល័យចំណូលសាធារណៈវិស័យសង្គមកិច្ច
- ការិយាល័យចំណូលសាធារណៈវិស័យសេដ្ឋកិច្ច។

**ប្រការ២០.-**

តួនាទី និងភារកិច្ចរបស់ការិយាល័យចំណូលសាធារណៈវិស័យរដ្ឋបាលទូទៅ, ការិយាល័យចំណូលសាធារណៈវិស័យការពារជាតិនិងសន្តិសុខ, ការិយាល័យចំណូលសាធារណៈវិស័យសង្គមកិច្ច, និងការិយាល័យចំណូលសាធារណៈវិស័យសេដ្ឋកិច្ច មានដូចខាងក្រោម÷

- ចូលរួមផ្តួចផ្តើម រៀបចំ និងកែសម្រួលលិខិតបទដ្ឋាននានា ដែលពាក់ព័ន្ធនឹងការផ្តល់សេវាសាធារណៈ និងការផ្តល់រង្វាន់លើកទឹកចិត្តរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងចូលរួមដោះស្រាយទំនាស់វិវាទនៃការប្រមូលចំណូលមិនមែនសារពើពន្ធ
- សិក្សាស្វែងយល់ស៊ីជម្រៅ អំពីប្រភពចំណូល និងនីតិវិធី បែបបទនៃការប្រមូលចំណូលនៅតាមក្រសួង ស្ថាប័ន មន្ទីរជំនាញ និងអង្គភាពរបស់រដ្ឋ
- ពិនិត្យឡើងវិញលើប្រភពចំណូលសាធារណៈ និងសេវារដ្ឋបាលរបស់រដ្ឋមួយចំនួន ដែលមានសក្តានុពល
- សិក្សាស្រាវជ្រាវរកប្រភពចំណូលសាធារណៈដទៃទៀត
- ប្រមូលផ្តុំស្ថិតិលម្អិតតាមប្រភេទសេវាសាធារណៈនីមួយៗ ដែលពាក់ព័ន្ធនឹងការប្រមូលចំណូលរបស់ក្រសួង ស្ថាប័ន មន្ទីរជំនាញ និងអង្គភាពរបស់រដ្ឋ
- តាមដាន និងពិនិត្យផ្ទៀងផ្ទាត់ការអនុវត្តចំណូលពីការផ្តល់សេវាសាធារណៈ និងការផ្តល់រង្វាន់លើកទឹកចិត្តនៅតាមក្រសួង ស្ថាប័ន មន្ទីរជំនាញ និងអង្គភាពរបស់រដ្ឋ

- សហការជាមួយក្រសួងស្ថាប័ន អនុវត្តការតឹងទារបំណុល និងលើកវិធានការតឹងទារ ឬជម្រះបំណុល
- រៀបចំលិខិតពិនិត្យបញ្ជាក់លើសលាប័ត្រចំណូលថវិកាជាតិ សម្រាប់ការអនុវត្តនីតិវិធីទូទាត់ប្រាក់រង្វាន់លើកទឹកចិត្តរបស់ក្រសួង ស្ថាប័ន រដ្ឋបាលកណ្តាល និងធ្វើកំណត់បង្ហាញជូនអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ ដើម្បីពិនិត្យ និងសម្រេច
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ស្តីពីស្ថានភាពនៃកាអនុវត្តចំណូល និងស្ថានភាពបំណុលរបស់ក្រសួង ស្ថាប័ន មន្ទីរជំនាញ និងអង្គភាពនៃរដ្ឋបាលថ្នាក់ជាតិ
- ចូលរួមរៀបចំគម្រោងថវិកាប្រចាំឆ្នាំ ក្នុងដំណើការរៀបចំសេចក្តីព្រាងច្បាប់ ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងនៃឆ្នាំនីមួយៗ
- ធ្វើរបាយការណ៍ទៀងទាត់ស្តីពីសកម្មភាពការងាររបស់ការិយាល័យសាមី។

**ប្រការ២១._**

ការិយាល័យចំណូលសាធារណៈវិស័យរដ្ឋបាលទូទៅទទួលបន្ទុកបំពេញភារកិច្ចលើការងារគ្រប់គ្រងចំណូលរបស់ក្រសួងព្រះបរមរាជវាំង, រដ្ឋសភា, ព្រឹទ្ធសភា, ក្រុមប្រឹក្សាធម្មនុញ្ញ, ទីស្តីការគណៈរដ្ឋមន្ត្រី, ក្រសួងមុខងារសាធារណៈ, ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា, ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច, ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ក្រសួងផែនការ, ក្រសួងយុត្តិធម៌, អាជ្ញាធរសវនកម្មជាតិ, និងស្ថាប័នប្រឆាំងអំពើពុករលួយ។

ការិយាល័យចំណូលសាធារណៈវិស័យរដ្ឋបាលទូទៅ ទទួលបន្ទុកធ្វើរបាយការណ៍សរុបស្តីពីសកម្មភាពការងាររបស់ការិយាល័យសាមី។

**ប្រការ២២._**

ការិយាល័យចំណូលសាធារណៈវិស័យការពារជាតិនិងសន្តិសុខទទួលបន្ទុកបំពេញភារកិច្ចលើការងារគ្រប់គ្រងចំណូលរបស់ក្រសួងការពារជាតិ និងក្រសួងមហាផ្ទៃ។

បន្ថែមលើភារកិច្ចដែលបានកំណត់នៅក្នុងប្រការ២០ នៃប្រកាសនេះ ការិយាល័យចំណូលសាធារណៈវិស័យការពារជាតិ និងសន្តិសុខមានភារកិច្ចគ្រប់គ្រងសន្និធិ និងបើកផ្តល់បង្កាន់ដៃបង់ប្រាក់ សម្រាប់ការប្រមូលចំណូលមិនមែនសារពើពន្ធ ព្រមទាំងធ្វើរបាយការណ៍អំពីស្ថានភាពបើកផ្តល់បង្កាន់ដៃបង់ប្រាក់ប្រចាំខែ ប្រចាំត្រីមាស និងប្រចាំឆ្នាំ។ លើកគម្រោងបោះពុម្ពបង្កាន់ដៃបង់ប្រាក់ប្រចាំឆ្នាំ សម្រាប់ការប្រើប្រាស់ប្រមូលចំណូលមិនមែនសារពើពន្ធរបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

**ប្រការ២៣._**

ការិយាល័យចំណូលសាធារណៈវិស័យសង្គមកិច្ចទទួលបន្ទុកបំពេញភារកិច្ចលើការងារគ្រប់គ្រងចំណូលរបស់ក្រសួងព័ត៌មាន, ក្រសួងសុខាភិបាល, ក្រសួងអប់រំ យុវជន និងកីឡា, ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ, ក្រសួងបរិស្ថាន, ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា, ក្រសួងធម្មការ និងសាសនា, ក្រសួងកិច្ចការនារី, និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**ប្រការ២៤.–**

ការិយាល័យចំណូលសាធារណៈវិស័យសេដ្ឋកិច្ចទទួលបន្ទុកបំពេញការងារគ្រប់គ្រងចំណូលរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល, ក្រសួងឧស្សាហកម្ម និងសិប្បកម្ម, ក្រសួងរ៉ែ និងថាមពល, ក្រសួងពាណិជ្ជកម្ម, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ក្រសួងអភិវឌ្ឍន៍ជនបទ, ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍, ក្រសួងសាធារណការ និងដឹកជញ្ជូន, ក្រសួងទេសចរណ៍, ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, និងក្រសួងធនធានទឹក និងឧតុនិយម។

**ជំពូកទី៦**

**នាយកដ្ឋានសហគ្រាសសាធារណៈ**

**ប្រការ២៥.–**

តួនាទី និងភារកិច្ចរបស់នាយកដ្ឋានសហគ្រាសសាធារណៈ នៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ មានដូចខាងក្រោម÷

- បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ លើការងារគ្រប់គ្រងសហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល និងអង្គភាពនីតិបុគ្គលសាធារណៈដទៃទៀត
- ផ្តួចផ្តើម និងចូលរួមរៀបចំសេចក្តីព្រាងច្បាប់ គោលនយោបាយ យុទ្ធសាស្ត្រ និងលិខិតបទដ្ឋាននានា ទាក់ទងនឹងការគ្រប់គ្រងសហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល និងអង្គភាពនីតិបុគ្គលសាធារណៈដទៃទៀត
- ជំរុញ និងជួយរៀបចំអង្គភាពរដ្ឋ រួមទាំងក្រុមហ៊ុនចំរុះរដ្ឋទាំងឡាយដែលជាគោលដៅនៃការកែទម្រង់សហគ្រាសរដ្ឋ ដើម្បីឱ្យអនុវត្តរបបសហគ្រាសសាធារណៈ ឬ ជម្រះបញ្ជី
- ជួយរៀបចំឯកសារគតិយុត្ត សម្រាប់បង្កើតសហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល និងអង្គភាពនីតិបុគ្គលសាធារណៈដទៃទៀត
- ពិនិត្យផែនការប្រចាំឆ្នាំ ចុះពិនិត្យការអនុវត្តប្រចាំឆ្នាំ និងពិនិត្យការបិទបញ្ជីគណនេយ្យប្រចាំឆ្នាំ ព្រមទាំងជំរុញការបង់ចំណូលថវិកាជាតិ របស់សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល និងអង្គភាពនីតិបុគ្គលសាធារណៈដទៃទៀត
- តាមដាន និងពិនិត្យស្ថានភាពហិរញ្ញវត្ថុរបស់សហគ្រាសសាធារណៈ និងគ្រឹះស្ថានសាធារណៈរដ្ឋបាល និងអង្គភាពនីតិបុគ្គលសាធារណៈដទៃទៀត
- ចូលរួមរៀបចំគម្រោងថវិកាប្រចាំឆ្នាំ ក្នុងដំណើរការរៀបចំសេចក្តីព្រាងច្បាប់ ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងនៃឆ្នាំនីមួយៗ។

**ប្រការ២៦.–**

នាយកដ្ឋានសហគ្រាសសាធារណៈ មានការិយាល័យក្រោមឱវាទចំនួនបី ដូចខាងក្រោម÷

- ការិយាល័យសហគ្រាសសាធារណៈ
- ការិយាល័យគ្រឹះស្ថានសាធារណៈរដ្ឋបាល

- ការិយាល័យអង្គភាពនីតិបុគ្គលសាធារណៈ។

**ប្រការ២៧.-**

តួនាទី និងភារកិច្ចរបស់ការិយាល័យសហគ្រាសសាធារណៈ មានដូចខាងក្រោម÷

- ចូលរួមផ្តួចផ្តើម និងរៀបចំគោលនយោបាយ យុទ្ធសាស្ត្រ និងលិខិតបទដ្ឋាននានា សម្រាប់ការកែទម្រង់សហគ្រាសសាធារណៈ ស្របតាមការរីកចម្រើននៃសេដ្ឋកិច្ចជាតិ
- ជំរុញ និងរៀបចំអង្គភាពរដ្ឋដែលជាគោលដៅនៃការទម្រង់ទៅជាសហគ្រាសសាធារណៈ
- ចូលរួមកំណត់ដើមទុនដំបូង ឬការជម្រះបញ្ជីសម្រាប់ការបង្កើត ការរំលាយបញ្ចូល ការបំបែក ឬការកែលម្អនៃសហគ្រាសសាធារណៈ
- ពិនិត្យការបិទបញ្ជីគណនេយ្យប្រចាំឆ្នាំ ព្រមទាំងតាមដានស្ថានភាពប្រែប្រួលនៃបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋប្រចាំឆ្នាំ របស់សហគ្រាសសាធារណៈនីមួយៗ
- ពិនិត្យ វាយតម្លៃនិងធ្វើការជម្រះបញ្ជីចលនទ្រព្យនិងអចលនទ្រព្យរបស់សហគ្រាសសាធារណៈ ដែលផុតអាយុកាលប្រើប្រាស់ ឬខូចខាត
- តាមដាន និងពិនិត្យជាប្រចាំ អំពីស្ថានភាពហិរញ្ញវត្ថុសហគ្រាសសាធារណៈ
- សម្របសម្រួលជាមួយសហគ្រាសសាធារណៈទាំងអស់ ក្នុងការរៀបចំគម្រោងចំណូលពីសហគ្រាសសាធារណៈ ដែលជាចំណូលបានពីប្រាក់ចំណេញ (ភាគលាភ) ដើម្បីបញ្ចូលទៅក្នុងសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំនីមួយៗ
- ពិនិត្យ និងលើកយោបល់ជូនថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមរយៈអគ្គនាយកដ្ឋានលើគម្រោងចំណូល ចំណាយ និងគម្រោងវិនិយោគប្រចាំឆ្នាំរបស់សហគ្រាសសាធារណៈ ដើម្បីធ្វើការពិនិត្យសម្រេច ក្នុងនាមជាក្រសួងអាណាព្យាបាលហិរញ្ញវត្ថុ
- ជំរុញការបង់ចំណូលចូលថវិកាជាតិរបស់សហគ្រាសសាធារណៈ
- ធ្វើរបាយការណ៍សរុបស្តីពីសកម្មភាពការងាររបស់សាមីការិយាល័យ និងរបស់នាយកដ្ឋានសហគ្រាសសាធារណៈ។

**ប្រការ២៨.-**

តួនាទី និងភារកិច្ចរបស់ការិយាល័យគ្រឹះស្ថានសាធារណៈរដ្ឋបាល មានដូចខាងក្រោម÷

- ចូលរួមផ្តួចផ្តើម និងរៀបចំគោលនយោបាយ យុទ្ធសាស្ត្រ និងលិខិតបទដ្ឋាននានា សម្រាប់ការកែទម្រង់គ្រឹះស្ថានសាធារណៈរដ្ឋបាល ស្របតាមការរីកចម្រើននៃសេដ្ឋកិច្ចជាតិ
- ជំរុញ និងរៀបចំអង្គភាពរដ្ឋដែលជាគោលដៅនៃការទម្រង់ទៅគ្រឹះស្ថានសាធារណៈរដ្ឋបាល
- ផ្តួចផ្តើម និងចូលរួមរៀបចំ និងពិនិត្យក្របខណ្ឌច្បាប់លិខិតបទដ្ឋានពាក់ព័ន្ធនានា រួមទាំងការកំណត់ដើមទុនដំបូង ការជម្រះបញ្ជីសម្រាប់ការបង្កើត ការបញ្ចូលគ្នា ការបែកចេញ ការប្រែប្រួល ការរំសាយ ឬ ការកែលម្អនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- ពិនិត្យការបិទបញ្ជីគណនេយ្យប្រចាំឆ្នាំ ព្រមទាំងតាមដានស្ថានភាពប្រែប្រួលនៃបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋប្រចាំឆ្នាំ របស់គ្រឹះស្ថានសាធារណៈរដ្ឋបាលនីមួយៗ

- ពិនិត្យ វាយតម្លៃ និងជម្រះចេញពីបញ្ជីសារពើភណ្ឌនូវចលនទ្រព្យ និងអចលនទ្រព្យរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាលដែលផុតអាយុកាលប្រើប្រាស់ ឬខូចខាត
- តាមដាន និងពិនិត្យជាប្រចាំ អំពីស្ថានភាពហិរញ្ញវត្ថុរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល
- ពិនិត្យគម្រោងថវិកាប្រចាំឆ្នាំរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល និងគម្រោងវិនិយោគរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ដើម្បីបញ្ចូលទៅក្នុងសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំនីមួយៗ
- ធ្វើរបាយការណ៍ទៀងទាត់ស្តីពីសកម្មភាពការងាររបស់សាមីការិយាល័យ។

**ប្រការ២៩.-**

តួនាទី និងភារកិច្ចរបស់ការិយាល័យអង្គភាពនីតិបុគ្គលសាធារណៈ មានដូចខាងក្រោម÷

- ចូលរួមផ្តួចផ្តើម និងរៀបចំគោលនយោបាយ យុទ្ធសាស្ត្រ និងលិខិតបទដ្ឋាននានា សម្រាប់ការកែទម្រង់អង្គភាពនីតិបុគ្គលសាធារណៈ ស្របតាមការរីកចម្រើននៃសេដ្ឋកិច្ចជាតិ
- គ្រប់គ្រងអង្គភាពនីតិបុគ្គលសាធារណៈ អង្គភាពរដ្ឋនានាដែលស្ថិតនៅក្រោមចំណុះរបស់ក្រសួង ស្ថាប័ន ដែលមានប្រភពចំណូលផ្សេងទៀតក្រៅពីថវិការដ្ឋ
- ជំរុញ និងរៀបចំអង្គភាពរដ្ឋ ឬអង្គភាពនីតិបុគ្គលសាធារណៈ ដែលជាគោលដៅនៃការទម្រង់ទៅជាសហគ្រាសសាធារណៈ ឬ គ្រឹះស្ថានសាធារណៈរដ្ឋបាល
- ពិនិត្យការបិទបញ្ជីគណនេយ្យប្រចាំឆ្នាំ ព្រមទាំងតាមដានស្ថានភាពប្រែប្រួលនៃបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋប្រចាំឆ្នាំរបស់អង្គភាពនីតិបុគ្គលសាធារណៈនីមួយៗ ហើយបញ្ជូនបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់អង្គភាពនីតិបុគ្គលសាធារណៈមួយច្បាប់ ដើម្បីតម្កល់ទុកនៅនាយកដ្ឋានសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ នៃអគ្គនាយកដ្ឋាន
- តាមដាន និងពិនិត្យជាប្រចាំ អំពីស្ថានភាពហិរញ្ញវត្ថុរបស់អង្គភាពនីតិបុគ្គលសាធារណៈ
- ពិនិត្យ វាយតម្លៃ និងជម្រះចេញពីបញ្ជីសាពើភណ្ឌនូវចលនទ្រព្យ និងអចលនទ្រព្យរបស់អង្គភាពនីតិបុគ្គលសាធារណៈ ដែលផុតអាយុកាលប្រើប្រាស់ ឬខូចខាត
- ពិនិត្យគម្រោងថវិកាប្រចាំឆ្នាំ និងគម្រោងវិនិយោគរបស់អង្គភាពនីតិបុគ្គលសាធារណៈ ដើម្បីបញ្ចូលទៅក្នុងសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំនីមួយៗ
- ធ្វើរបាយការណ៍ទៀងទាត់ស្តីពីសកម្មភាពការងាររបស់សាមីការិយាល័យ។

## ជំពូកទី៧
## នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន

**ប្រការ៣០.-**

តួនាទី និងភារកិច្ចរបស់នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន នៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ មានដូចខាងក្រោម÷

- បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ លើការងារគ្រប់គ្រង បញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ការរៀបចំផែនការ និងការអនុវត្តផែនការប្រមូលចំណូល និងបំណុលមិនមែនសារពើពន្ធមានលក្ខណៈប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន
- រៀបចំយុទ្ធសាស្ត្រគ្រប់គ្រងកិច្ចដំណើរការប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន លើការងារប្រមូលចំណូលមិនមែនសារពើពន្ធ និងគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ
- រៀបចំ និងគ្រប់គ្រងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់គ្រប់គ្រងការប្រមូលចំណូលនិងបំណុលមិនមែនសារពើ-ពន្ធ និងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ
- ចូលរួមផ្តួចផ្តើមរៀបចំសេចក្តីព្រាងច្បាប់ គោលនយោបាយ យុទ្ធសាស្ត្រ លិខិតបទដ្ឋាន និងយន្តការនានា ទាក់ទងនឹងការប្រមូលចំណូល និងបំណុលមិនមែនសារពើពន្ធ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ
- ចូលរួមសហការលើការងាររៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ ការងារតាមដានការអនុវត្តថវិកាកម្មវិធីផ្នែកចំណូលរបស់ក្រសួងស្ថាប័ន រៀបចំគម្រោងស្តីពីការប្រមូល ការតាមដាន និងការកត់ត្រាចំណូលនិងបំណុលមិនមែនសារពើពន្ធ ជាមួយក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ
- ពិនិត្យ និងផ្តល់យោបល់ជូនថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមរយៈអគ្គនាយកដ្ឋាន លើរាល់ការងារប្រមូលចំណូល និងគម្រោងកម្មវិធីប្រមូលចំណូលមិនមែនសារពើពន្ធដែលប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់ក្រសួង ស្ថាប័ន រួមទាំងអង្គភាពក្រោមឱវាទ និងនីតិបុគ្គលសាធារណៈ
- រៀបចំ និងគ្រប់គ្រងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន សម្រាប់គ្រប់គ្រងអចលនទ្រព្យ ចលនទ្រព្យ សន្និធិសម្ភារ និងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់អគ្គនាយកដ្ឋាន
- រៀបចំ និងគ្រប់គ្រងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន សម្រាប់គ្រប់គ្រងការងាររដ្ឋបាល បុគ្គលិក គណនេយ្យ ហិរញ្ញវត្ថុ ការអនុវត្តថវិកាកម្មវិធី និងការងារដទៃទៀតរបស់អគ្គនាយកដ្ឋាន
- គ្រប់គ្រង ថែរក្សា ការពារប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន រួមទាំងទិន្នន័យនៃការគ្រប់គ្រងការប្រមូលចំណូល និងបំណុលមិនមែនសារពើពន្ធ បញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ និងទិន្នន័យពាក់ព័ន្ធដទៃទៀតរបស់អគ្គនាយកដ្ឋាន
- រៀបចំ គ្រប់គ្រង និងអភិវឌ្ឍ គេហទំព័រ បណ្តាញផ្សព្វផ្សាយ និងបណ្តាញទំនាក់ទំនងសង្គម របស់អគ្គនាយកដ្ឋាន
- ទទួលបន្ទុកគ្រប់គ្រង បែងចែក និងលើកសំណើលើការបំពាក់សម្ភារ បរិក្ខារបច្ចេកវិទ្យាព័ត៌មានរបស់អគ្គនាយកដ្ឋាន
- ផ្តល់សេវា និងការបណ្តុះបណ្តាល លើផ្នែកបច្ចេកវិទ្យាព័ត៌មានដល់នាយកដ្ឋាននានាចំណុះអគ្គនាយកដ្ឋាន និងក្រសួង ស្ថាប័ន អង្គភាពដទៃទៀត
- ស្រាវជ្រាវ និងអភិវឌ្ឍលើការធ្វើទំនើបកម្មនៃការគ្រប់គ្រងការងាររបស់អគ្គនាយកដ្ឋានឱ្យមានលក្ខណៈជាប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន
- រៀបចំនិងពិនិត្យផ្តល់យោបល់លើឯកសារស្នើសុំពាក់ព័ន្ធនឹងសម្បទានរ៉ែ
- គ្រប់គ្រងចំណូល ប្រាក់កក់ និងបំណុល និងតាមដានការអនុវត្តកិច្ចសន្យា សៀវភៅបន្ទុក ពីសម្បទានរ៉ែ
- ទទួលបន្ទុកដោយឡែកបន្ថែមទៀត តាមការចាំបាច់ និងចាត់តាំងរបស់អគ្គនាយក។

ប្រការ៣១._

នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន មានការិយាល័យក្រោមឱវាទចំនួនបី ដូចខាងក្រោម÷

- ការិយាល័យបច្ចេកវិទ្យាព័ត៌មាននៃចំណូលមិនមែនសារពើពន្ធ
- ការិយាល័យបច្ចេកវិទ្យាព័ត៌មាននៃបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ
- ការិយាល័យសេវាបច្ចេកវិទ្យាព័ត៌មាន។

ប្រការ៣២._

តួនាទី និងភារកិច្ចរបស់ការិយាល័យបច្ចេកវិទ្យាព័ត៌មាននៃចំណូលមិនមែនសារពើពន្ធ មានដូចខាងក្រោម÷

- រៀបចំ និងគ្រប់គ្រងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់គ្រប់គ្រងការរៀបចំផែនការចំណូល និងការអនុវត្តចំណូលមិនមែនសារពើពន្ធ
- រៀបចំយុទ្ធសាស្ត្រគ្រប់គ្រងកិច្ចដំណើរការប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានលើការងារប្រមូលចំណូលមិនមែនសារពើពន្ធ
- សម្របសម្រួលជាមួយនាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធ ដើម្បីធ្វើការគ្រប់គ្រងការប្រមូលចំណូល និងបំណុលមិនមែនសារពើពន្ធ ឱ្យកាន់តែមានប្រសិទ្ធភាព តាមរយៈប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន
- សម្របសម្រួល និងចូលរួមសហការលើការងារតាមដាន និងកត់ត្រាចំណូលនិងបំណុលមិនមែនសារពើពន្ធតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន
- រៀបចំ និងគ្រប់គ្រងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន សម្រាប់គ្រប់គ្រងការអនុវត្តការប្រមូលចំណូលតាមកិច្ចសន្យាសៀវភៅបន្ទុក ពីការជួល វិនិយោគ សម្បទាន និងការធ្វើ ឯកជនភាវូបនីយកម្មទ្រព្យសម្បត្តិរបស់រដ្ឋ
- រៀបចំ និងគ្រប់គ្រងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន សម្រាប់គ្រប់គ្រងការអនុវត្តការប្រមូលចំណូលពីការផ្តល់សេវាសាធារណៈ និងការផ្តល់រង្វាន់លើកទឹកចិត្តនៅតាមក្រសួង ស្ថាប័ន មន្ទីរជំនាញ និងនីតិបុគ្គលសាធារណៈ
- ពិនិត្យ និងផ្តល់យោបល់លើរាល់ការងារប្រមូលចំណូល និងគម្រោងកម្មវិធីប្រមូលចំណូលមិនមែនសារពើពន្ធដែលប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន របស់ក្រសួង ស្ថាប័ន រួមទាំងអង្គភាពក្រោមឱវាទ និងនីតិបុគ្គល-សាធារណៈ
- រក្សាការពារទិន្នន័យ និងប្រព័ន្ធនៃការគ្រប់គ្រងការប្រមូលចំណូល និងបំណុលមិនមែនសារពើពន្ធ
- ផ្តល់សេវា និងការបណ្តុះបណ្តាល លើផ្នែកបច្ចេកវិទ្យាព័ត៌មានពាក់ព័ន្ធនឹងប្រព័ន្ធគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- ធ្វើរបាយការណ៍ទៀងទាត់ស្តីពីសកម្មភាពការងាររបស់សាមីការិយាល័យ
- អនុវត្តភារកិច្ចដទៃទៀត តាមការចាំបាច់ និងចាត់តាំងរបស់ប្រធាននាយកដ្ឋាន។

ប្រការ៣៣._

តួនាទី និងភារកិច្ចរបស់ការិយាល័យបច្ចេកវិទ្យាព័ត៌មាននៃបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ មានដូចខាងក្រោម÷

- រៀបចំយុទ្ធសាស្ត្រគ្រប់គ្រងកិច្ចដំណើរការប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានលើការងារគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ

- រៀបចំ និងគ្រប់គ្រងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់តាមដាន និងគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់ក្រសួង ស្ថាប័ន និងអង្គភាពនីតិបុគ្គលសាធារណៈ
- សម្របសម្រួល និងចូលរួមពិនិត្យលើការងារកត់ត្រា និងជម្រះបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋនៅក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន
- រក្សាការពារទិន្នន័យ និងប្រព័ន្ធនៃការគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ
- ផ្តល់សេវា និងការបណ្តុះបណ្តាល លើផ្នែកបច្ចេកវិទ្យាព័ត៌មានពាក់ព័ន្ធនឹងប្រព័ន្ធគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យ-សម្បត្តិរដ្ឋ ដល់ក្រសួងស្ថាប័ន និងអង្គភាពពាក់ព័ន្ធ
- ធ្វើរបាយការណ៍ទៀងទាត់ស្តីពីសកម្មភាពការងាររបស់សាមីការិយាល័យ
- អនុវត្តភារកិច្ចដទៃទៀត តាមការចាត់ចែង និងចាត់តាំងរបស់ប្រធាននាយកដ្ឋាន។

**ប្រការ៣៤.-**

តួនាទី និងភារកិច្ចរបស់ការិយាល័យសេវាបច្ចេកវិទ្យាព័ត៌មាន មានដូចខាងក្រោម÷

- រៀបចំយុទ្ធសាស្ត្រគ្រប់គ្រងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់បំរើដល់កិច្ចការទូទៅរបស់អគ្គនាយកដ្ឋាន
- រៀបចំ និងគ្រប់គ្រងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន សម្រាប់គ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យ សន្និធិសម្ភារ និងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់អគ្គនាយកដ្ឋាន
- រៀបចំ និងគ្រប់គ្រងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន សម្រាប់គ្រប់គ្រងការងាររដ្ឋបាល បុគ្គលិក គណនេយ្យ ហិរញ្ញវត្ថុ ការអនុវត្តថវិកាកម្មវិធី និងការងារដទៃទៀតរបស់អគ្គនាយកដ្ឋាន
- រៀបចំ គ្រប់គ្រង និងអភិវឌ្ឍគេហទំព័រ បណ្តាញផ្សព្វផ្សាយ និងបណ្តាញទំនាក់ទំនងសង្គម របស់អគ្គនាយកដ្ឋាន
- ផ្តល់សេវា និងការបណ្តុះបណ្តាល លើផ្នែកបច្ចេកវិទ្យាព័ត៌មានទូទៅ
- វិភាគមុខងារ និងតម្រូវការ តាមនាយកដ្ឋាននីមួយៗ លើសម្ភារៈបច្ចេកវិទ្យាព័ត៌មាន
- គ្រប់គ្រង បែងចែក និងថែរក្សា រាល់សម្ភារបរិក្ខារបច្ចេកវិទ្យាព័ត៌មានទាំងអស់របស់អគ្គនាយកដ្ឋាន
- ធ្វើរបាយការណ៍ទៀងទាត់ស្តីពីសកម្មភាពការងាររបស់សាមីការិយាល័យ
- អនុវត្តភារកិច្ចដទៃទៀត តាមការចាត់ចែង និងចាត់តាំងរបស់ប្រធាននាយកដ្ឋាន។

## ជំពូកទី៨

## លេខាធិការដ្ឋាន

**ប្រការ៣៥.-**

លេខាធិការដ្ឋាននៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធបំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធលើបេសកកម្មដូចតទៅ÷

- ជាជំនួយការឱ្យអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ ក្នុងការសម្របសម្រួលការងារជាមួយនាយកដ្ឋាន និងការិយាល័យរបស់អគ្គនាយកដ្ឋាន

- ធ្វើជាលេខាធិការឱ្យអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ លើការងាររដ្ឋបាល បុគ្គលិក ហិរញ្ញវត្ថុ គណនេយ្យ និងការបណ្តុះបណ្តាល
- ដើរតួនាទីជាច្រកចេញចូលតែមួយរបស់អគ្គនាយកដ្ឋាន
- សម្របសម្រួល និងសហការរៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង និងច្បាប់ទូទាត់ថវិកាប្រចាំឆ្នាំនីមួយៗ
- បូកសរុបរបាយការណ៍នៃការប្រជុំ ការប្រមូលចំណូល និងបំណុលមិនមែនសារពើពន្ធ និងសកម្មភាពការងារដទៃទៀតរបស់អគ្គនាយកដ្ឋាន
- ទទួលបន្ទុកដោយឡែកបន្ថែមទៀត តាមការចាំបាច់ និងចាត់តាំងរបស់អគ្គនាយក។

## ជំពូកទី៩
## អវសានប្បញ្ញត្តិ

**ប្រការ៣៦.-**

ក្នុងការបំពេញភារកិច្ចទាំងឡាយណាដែលពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់អគ្គនាយដ្ឋាន នាយកដ្ឋានជំនាញដទៃនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ ត្រូវសហការជាមួយអគ្គនាយកដ្ឋានពាក់ព័ន្ធទាំងនោះរួមគ្នាដោះស្រាយ ឬសុំការសម្រេចពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លើការកំណត់ ឬបែងចែកភារកិច្ចទាំងនោះ។

**ប្រការ៣៧.-**

ត្រូវបានទុកជានិរាករណ៍ នូវប្រកាសដូចខាងក្រោម÷

- ប្រកាសលេខ ១៧១ សហវ.ប្រក ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០០១ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ប្រកាសលេខ ២៣៦ សហវ.ប្រក ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០០៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃនាយក-ដ្ឋានចំណូលមិនមែនសារពើពន្ធ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ប្រកាសលេខ ១៤៧ សហវ.ប្រក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការបង្កើតការិយាល័យសម្បទានដីសេដ្ឋកិច្ច បន្ថែមលើប្រកាសលេខ ១៧១ សហវ.ប្រក ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ប្រកាសលេខ ១៤១០ សហវ.ប្រក ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃនាយកដ្ឋាន និងអង្គភាពក្រោមឱវាទរបស់អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ៣៨.-**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ អគ្គលេខាធិការ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន និងអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាស នេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ។

ថ្ងៃព្រហស្បតិ៍ ៥រោច ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែមេសា ឆ្នាំ២០១៨

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

បណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច/ឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលារាជធានីខេត្ត
- ដូចប្រការ៣៨
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធនៃប្រកាសលេខ................
ចុះថ្ងៃ ខែ ឆ្នាំ ស័ក ព.ស.២៥៦
ត្រូវនឹងថ្ងៃទី ខែ ឆ្នាំ២០១៨

# អង្គការលេខនៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ



**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ [illegible] សហវ.ប្រក

# ប្រកាសអន្តរក្រសួង
## ស្តីពី
## ការតែងតាំងរជ្ជទេយ្យករបុរេប្រទាន
## ប្រចាំនៅសាលាជាតិកសិកម្មព្រែកលៀបនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/ន.ស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៣/០០៤ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការធ្វើវិសោធនកម្មមាត្រា៩ និងមាត្រា១០ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ: ៨៥៥-២៣-៤២៧ ៧៩៨
Phone 855-23-724 664 Fax : 855-23-427 798

- បានឃើញអនុក្រឹត្យលេខ១៩ អនក្រ.បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមាត្រា៤៤ មាត្រា៤៥ មាត្រា៤៦ និងមាត្រា៤៧ នៃអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៧ ៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីកាកែសម្រួលអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១០៥ អនក្រ.បក ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៥ ស្តីពីការបន្ថែមមុខងារភារកិច្ចឲ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានផែនការនិងស្ថិតិ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងមជ្ឈមណ្ឌលព័ត៌មាននិងឯកសារកសិកម្មចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផលឲ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រនិងកែលម្អដីកសិកម្ម ឲ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ២២៤ អនក្រ.បក ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៦ ស្តីពីការដំឡើងនាយកដ្ឋានផលិតកម្មនិងបសុព្យាបាលទៅជាអគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៥ ស្តីពីលក្ខន្តិកៈគតិយុត្តិនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ១៣៩ អនក្រ.បក ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ១៩៩៦ ស្តីពីការគ្រប់គ្រងថវិកា និងទ្រព្យសម្បត្តិរដ្ឋ នៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ៨៤ អនក្រ.បក ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០០២ ស្តីពីការបង្កើតសាលាជាតិកសិកម្មព្រែកលៀបជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពី ការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិកា នៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ០០៤ សហវ.ម.ប្រក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការអនុវត្តបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ១៣៩៦ សហវ.ប្រក ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៦ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់គ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ១៧១ សហវ.ប្រក ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៧ ស្តីពីនីតិវិធីអនុវត្តថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញប្រកាសលេខ១៧២ សហវ.ប្រក ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការប្រគល់សិទ្ធិជាអភិបាលហិរញ្ញវត្ថុ ជូនមន្ត្រីហិរញ្ញវត្ថុប្រចាំគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញប្រកាសលេខ១២១២ សហវ.ប្រក ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តមាតិកាគណនីនៃប្លង់គណនេយ្យសាធារណៈ

- យោងតាមតម្រូវការចាំបាច់នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងសាលាជាតិកសិកម្មព្រែកលៀប នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សម្រេច

**ប្រការ១ ._**

ត្រូវបានតែងតាំងរដ្ឋទេយ្យករបុរេប្រទាន និងរដ្ឋទេយ្យករបុរេប្រទានរង ប្រចាំនៅសាលាជាតិកសិកម្មព្រែកលៀប ដែលមានសមាសភាពដូចខាងក្រោមៈ

១-កញ្ញា **អ៊ុក សេរីសុខា** អនុប្រធានការិយាល័យគណនេយ្យហិរញ្ញវត្ថុទទួលបន្ទុកជារដ្ឋទេយ្យករបុរេប្រទាន

២-កញ្ញា **ប្រាក់ ចិន្តា** មន្ត្រីការិយាល័យគណនេយ្យហិរញ្ញវត្ថុ ទទួលបន្ទុកជារដ្ឋទេយ្យករបុរេប្រទានរង

**ប្រការ២._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៣._**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងនាយកសាលាជាតិកសិកម្មព្រែកលៀប ប្រធានគ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ព្រមទាំងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ[illegible] ខែ[illegible] ឆ្នាំរកា នព្វស័ក ព.ស.២៥៦១

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ២១ ខែមីនា ឆ្នាំ២០១៨

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**បណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**

**កន្លែងទទួលៈ**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងមុខងារសាធារណៈ
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតី តេជោ នាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
-ដូចប្រការ៣
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ...........សហវ.

**ប្រកាសអន្តរក្រសួង**
**ស្តីពី**
**ការបង្កើតរជ្ជទេយ្យបុរេប្រទានប្រចាំឆ្នាំ២០១៨**
**នៅសាលាជាតិកសិកម្ម ព្រែកលៀប នៃក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជ ក្រមលេខ០២/នស/រកម/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ,
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ,
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ,
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៧/០១៩ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨
- បានឃើញអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ១៩ អនក្រ.បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមាត្រា៤៤ មាត្រា៤៥ មាត្រា៤៦ និងមាត្រា៤៧ នៃអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីកាកែសម្រួលអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, khan Daun Penh, Phnom Penh, CAMBODIA.
ទូរសព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១០៥ អនក្រ.បក ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៥ ស្តីពីការបន្ថែមមុខងារភារកិច្ចឲ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានផែនការនិងស្ថិតិ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងមជ្ឈមណ្ឌលព័ត៌មាននិងឯកសារកសិកម្មចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផលឲ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រនិងកែលម្អដីកសិកម្ម ឲ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ២២៤ អនក្រ.បក ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៦ ស្តីពីការដំឡើងនាយកដ្ឋានផលិតកម្មនិងបសុព្យាបាលទៅជាអគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ
- បានឃើញអនុក្រឹត្យលេខ៨៤ អនក្រ.បក ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០០២ ស្តីពីការបង្កើតសាលាជាតិកសិកម្មព្រែកលៀបជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ១៣៩ អនក្រ.បក ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ១៩៩៦ ស្តីពីការគ្រប់គ្រងថវិកា និងទ្រព្យ-សម្បត្តិរដ្ឋ នៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញប្រកាសលេខ១៧១ សហវ.ប្រក ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីនីតិវិធីអនុវត្តថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញប្រកាសលេខ១៧២ សហវ.ប្រក ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការប្រគល់សិទ្ធិជាអភិបាលហិរញ្ញវត្ថុជូនមន្ត្រីហិរញ្ញវត្ថុ ប្រចាំគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋ នៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញនិងអង្គការសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ០០៤ សហវ.ម.ប្រក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការអនុវត្តបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ១២១២ សហវ.ប្រក ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការដាក់ឲ្យអនុវត្តមាតិកាគណនីនៃប្លង់គណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ៥២៣ សហវ.ប្រក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការដាក់ឲ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ១៣៩៦ សហវ.ប្រក ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៦ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់គ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញប្រកាសលេខ១១២/១៩០ប្រក.កសក.គហ ចុះថ្ងៃពុធ ១៤រោច ខែមាឃ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ ត្រូវនឹងថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១៨ ស្តីពីការតែងតាំងអាណាប័កផ្ទេរសិទ្ធរបស់សាលាជាតិកសិកម្មព្រែកលៀប
- យោងតាមតម្រូវការចាំបាច់នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងសាលាជាតិកសិកម្មព្រែកលៀបនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សម្រេច

**ប្រការ១._**

ត្រូវបានបង្កើតរជ្ជទេយ្យបុរេប្រទានថវិកាកម្មវិធីជំពូក៦០"ការទិញ" ជំពូក៦១"សេវាកម្ម" ជំពូក៦២"អត្ថប្រយោជន៍សង្គម" និងជំពូក៦៤"បន្ទុកបុគ្គលិក" នៅសាលាជាតិកសិកម្មព្រែកលៀប នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សម្រាប់មុខសញ្ញាចំណាយ ដូចមានចែងក្នុងប្រការ៥ នៃប្រកាសលេខ១៣៩៦ សហវ.ប្រក ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៦ ស្ដីពីនីតិវិធីចំណាយរជ្ជទេយ្យបុរេប្រទានសម្រាប់គ្រឹះស្ថានសាធារណៈរដ្ឋបាល។

តារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទាន ត្រូវបានកំណត់ជាឧបសម្ព័ន្ធ នៃប្រកាសអន្តរក្រសួងនេះ។

**ប្រការ២._**

ចំនួនទឹកប្រាក់១ជុំបង្វិល នៃរជ្ជទេយ្យបុរេប្រទាន ត្រូវកំណត់ដូចក្នុងតារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទាន។

**ប្រការ៣._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៤._**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងនាយកសាលាជាតិកសិកម្មព្រែកលៀប ប្រធានគ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃអង្គារ ១០រោច ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៨

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**បណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រី**
**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**

**កន្លែងទទួល :**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្ដម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
សាលាជាតិកសិកម្មព្រែកលៀប

## តារាងឧបសម្ព័ន្ធរដ្ឋទេយ្យបុរេប្រទានថវិកាកម្មវិធីតាមចំណាត់ថ្នាក់សេដ្ឋកិច្ចឆ្នាំ២០១៨ របស់សាលាជាតិកសិកម្មព្រែកលៀប

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណាយ | ច្បាប់ថវិកា២០១៨ | ឥណទានដែលជ្រើសរើស | ឥណទានរដ្ឋទេយ្យបុរេប្រទាន | ឥណទានទូទាត់ធម្មតា | ឥណទាន១ជុំបង្វិលរដ្ឋទេយ្យបុរេប្រទាន | ភាគរយ |
|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤= ២- ៣ | ៥= ៣/ ៤ =១ជុំ | ៦= ៣/ ២ |
| | | | សរុបរួម | 4,334,900,000 | 2,875,900,000 | 1,232,800,000 | 1,643,100,000 | 308,200,000 | 43% |
| 60 | | | ការទិញ | 2,239,500,000 | 1,466,500,000 | 396,500,000 | 1,070,000,000 | 99,125,000 | 27% |
| | 6001 | | សម្ភារៈផ្គត់ផ្គង់ថែទាំ | 353,700,000 | 353,700,000 | 153,700,000 | 200,000,000 | 38,425,000 | 43% |
| | | 60011 | សម្ភារៈផ្គត់ផ្គង់សម្អាតនិងអនាម័យ | 32,500,000 | 32,500,000 | 32,500,000 | | 8,125,000 | 100% |
| | | 60012 | សម្ភារៈផ្គត់ផ្គង់សម្រាប់ថែទាំអគារ ប្រាសាទ និងសំណង់ផ្សេងៗ | 50,000,000 | 50,000,000 | 25,000,000 | 25,000,000 | 6,250,000 | 50% |
| | | 60013 | សម្ភារៈផ្គត់ផ្គង់សម្រាប់ថែទាំផ្លូវថ្នល់ ស្ពាន និងលូ | 21,400,000 | 21,400,000 | 21,400,000 | | 5,350,000 | 100% |
| | | 60014 | សម្ភារៈផ្គត់ផ្គង់សម្រាប់ថែទាំសម្ភារៈឧបករណ៍ | 50,000,000 | 50,000,000 | 25,000,000 | 25,000,000 | 6,250,000 | 50% |
| | | 60015 | ប្រេងឥន្ធនៈនិងប្រេងរំអិល | 189,800,000 | 189,800,000 | 39,800,000 | 150,000,000 | 9,950,000 | 21% |
| | | 60018 | សម្ភារៈផ្គត់ផ្គង់សម្រាប់ថែទាំផ្សេងៗ | 10,000,000 | 10,000,000 | 10,000,000 | | 2,500,000 | 100% |
| | 6002 | | សម្ភារៈផ្គត់ផ្គង់ផ្នែករដ្ឋបាល | 182,700,000 | 182,700,000 | 72,700,000 | 110,000,000 | 18,175,000 | 40% |
| | | 60021 | សម្ភារៈការិយាល័យ | 97,900,000 | 97,900,000 | 7,900,000 | 90,000,000 | 1,975,000 | 8% |
| | | 60022 | សៀវភៅមើល និង ឯកសារ | 20,000,000 | 20,000,000 | 20,000,000 | | 5,000,000 | 100% |
| | | 60023 | ការបោះពុម្ព | 20,000,000 | 20,000,000 | 20,000,000 | | 5,000,000 | 100% |
| | | 60028 | សម្ភារៈផ្គត់ផ្គង់ផ្នែករដ្ឋបាលផ្សេងៗ | 44,800,000 | 44,800,000 | 24,800,000 | 20,000,000 | 6,200,000 | 55% |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | 6003 | | សម្ភារៈតូចតាច សង្ហារឹម និងសម្ភារៈបរិក្ខារ | 144,300,000 | 144,300,000 | 124,300,000 | 20,000,000 | 31,075,000 | 86% |
| | | 60031 | សៀវ | 9,500,000 | 9,500,000 | 9,500,000 | | 2,375,000 | 100% |
| | | 60032 | ចំណីសត្វ | 20,000,000 | 20,000,000 | 20,000,000 | | 5,000,000 | 100% |
| | | 60033 | ពូជ និងកូនរុក្ខជាតិ | 31,000,000 | 31,000,000 | 31,000,000 | | 7,750,000 | 100% |
| | | 60034 | ផលិតផលការពារសុខុមាលភាពរុក្ខជាតិ និងជី | 21,000,000 | 21,000,000 | 21,000,000 | | 5,250,000 | 100% |
| | | 60035 | ពូជសត្វ | 5,000,000 | 5,000,000 | 5,000,000 | | 1,250,000 | 100% |
| | | 60036 | និសថ និងវត្ថុធាតុសម្រាប់បសុពេទ្យ | 7,800,000 | 7,800,000 | 7,800,000 | | 1,950,000 | 100% |
| | | 60037 | សៀវសម្រាប់រដ្ឋបាល | 40,000,000 | 40,000,000 | 20,000,000 | 20,000,000 | 5,000,000 | 50% |
| | | 60038 | សៀវអាហារ និងផលិតកម្មកសិកម្មផ្សេងៗ | 10,000,000 | 10,000,000 | 10,000,000 | | 2,500,000 | 100% |
| | 6004 | | សំលៀកបំពាក់និងការតុបតែង | 40,000,000 | | | | | |
| | | 60041 | ឯកសណ្ឋាន | 40,000,000 | | | | | |
| | 6005 | | សម្ភារៈតូចតាច សង្ហារឹម និងសម្ភារៈបរិក្ខារ | 803,800,000 | 465,800,000 | 25,800,000 | 440,000,000 | 6,450,000 | 6% |
| | | 60051 | សម្ភារៈនិងបរិក្ខារបច្ចេកទេសមិនមែនព័ត៌មានវិទ្យា | 57,400,000 | 57,400,000 | 400,000 | 57,000,000 | 100,000 | 1% |
| | | 60052 | សង្ហារឹម | 53,200,000 | 53,200,000 | 200,000 | 53,000,000 | 50,000 | 0% |
| | | 60053 | សម្ភារៈប្រើប្រាស់ | 10,600,000 | 10,600,000 | 600,000 | 10,000,000 | 150,000 | 6% |
| | | 60054 | សម្ភារៈ និងឧបករណ៍ដឹកជញ្ជូន | 290,000,000 | 290,000,000 | 20,000,000 | 270,000,000 | 5,000,000 | 7% |
| | | 60055 | សម្ភារៈនិងបរិក្ខារបច្ចេកទេសព័ត៌មានវិទ្យា | 338,000,000 | | | | | |
| | | 60058 | សម្ភារៈតូចតាច សង្ហារឹម និងសម្ភារៈបរិក្ខារផ្សេងៗ | 54,600,000 | 54,600,000 | 4,600,000 | 50,000,000 | 1,150,000 | 8% |
| | 6006 | | ថាមពលនិងទឹក | 395,000,000 | | | | | |
| | | 60061 | អគ្គិសនី | 350,000,000 | | | | | |
| | | 60062 | ទឹក | 45,000,000 | | | | | |
| | 6007 | | សម្ភារៈបរិក្ខារថែទាំសុខភាព | 320,000,000 | 320,000,000 | 20,000,000 | 300,000,000 | 5,000,000 | 6% |
| | | 60078 | សម្ភារៈបរិក្ខារថែទាំសុខភាពផ្សេងៗ | 320,000,000 | 320,000,000 | 20,000,000 | 300,000,000 | 5,000,000 | 6% |
| 61 | | | សេវាកម្ម | 1,586,200,000 | 916,200,000 | 473,100,000 | 443,100,000 | 118,275,000 | 52% |
| | 6101 | | កិច្ចសន្យានៃការផ្ដល់សេវាជាមួយសហគ្រាស | 7,200,000 | 7,200,000 | 7,200,000 | | 1,800,000 | 100% |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | 61011 | សេវាអនាម័យ | 7,200,000 | 7,200,000 | 7,200,000 | | ,800,000 | 100% |
| | 6104 | | **សោហ៊ុយបណ្តុះបណ្តាលបុគ្គលិក ក្នុងនិងក្រៅប្រទេស** | **25,000,000** | **25,000,000** | **25,000,000** | | **6,250,000** | **100%** |
| | | 61041 | សោហ៊ុយបណ្តុះបណ្តាលក្នុងនិងក្រៅប្រទេស | 25,000,000 | 25,000,000 | 25,000,000 | | 6,250,000 | 100% |
| | 6105 | | **ការថែទាំនិងជួសជុល** | **876,400,000** | **226,400,000** | **116,400,000** | **110,000,000** | **29,100,000** | **51%** |
| | | 61051 | ការថែទាំដីធ្លី សួនច្បារ ព្រៃឈើ តំបន់ឆ្នេរ និងដែនទេសាទ | 70,000,000 | 70,000,000 | 35,000,000 | 35,000,000 | 8,750,000 | 50% |
| | | 61052 | ការថែទាំ ជួសជុលអគារផ្សេងៗ និងប្រាសាទ | 610,000,000 | | | | | |
| | | 61053 | ការថែទាំ ជួសជុលផ្លូវ ផ្លូវលំ ស្ពាន និងលូ | 58,000,000 | 58,000,000 | 33,000,000 | 25,000,000 | 8,250,000 | 57% |
| | | 61054 | ការថែទាំបណ្តាញផ្សេងៗ | 40,000,000 | | | | | |
| | | 61056 | ការថែទាំ និងជួសជុលមធ្យោបាយដឹកជញ្ជូន | 60,000,000 | 60,000,000 | 30,000,000 | 30,000,000 | 7,500,000 | 50% |
| | | 61057 | ការថែទាំនិងជួសជុលសម្ភារៈ និងឧបករណ៍បច្ចេកទេស | 38,400,000 | 38,400,000 | 18,400,000 | 20,000,000 | 4,600,000 | 48% |
| | 6107 | | **សោហ៊ុយសិក្សាពិ. នៃការប្រើប្រាស់សេវា និងនៃការប្រើប្រាស់សិទ្ធិ** | **250,000,000** | **250,000,000** | **100,000,000** | **150,000,000** | **25,000,000** | **40%** |
| | | 61071 | សោហ៊ុយសិក្សាពិសោធន៍ | 250,000,000 | 250,000,000 | 100,000,000 | 150,000,000 | 25,000,000 | 40% |
| | 6110 | | **ទំនាក់ទំនងសាធារណៈនិងផ្សព្វផ្សាយ** | **165,000,000** | **165,000,000** | **115,000,000** | **50,000,000** | **28,750,000** | **70%** |
| | | 61101 | សោហ៊ុយទទួលភ្ញៀវជាតិ | 30,000,000 | 30,000,000 | 30,000,000 | | 7,500,000 | 100% |
| | | 61102 | សោហ៊ុយទទួលភ្ញៀវបរទេស | 30,000,000 | 30,000,000 | 30,000,000 | | 7,500,000 | 100% |
| | | 61103 | ប្រជុំ សិក្ខាសាលា និងសន្និសីទ | 80,000,000 | 80,000,000 | 30,000,000 | 50,000,000 | 7,500,000 | 38% |
| | | 61104 | ចំណាយរៀបចំពិធីបុណ្យ | 5,000,000 | 5,000,000 | 5,000,000 | | 1,250,000 | 100% |
| | | 61106 | ចំណាយសម្រាប់ការតាំងពិពណ៌ នៅក្នុងនិងក្រៅប្រទេស | 20,000,000 | 20,000,000 | 20,000,000 | | 5,000,000 | 100% |
| | 6111 | | **សារព័ត៌មាន និងឯកសារ** | **5,200,000** | **5,200,000** | **5,200,000** | | **1,300,000** | **100%** |
| | | 61111 | ចំណាយលើការជាវសារព័ត៌មាន | 5,200,000 | 5,200,000 | 5,200,000 | | 1,300,000 | 100% |
| | 6112 | | **ចំណាយទូទាត់សោហ៊ុយក្នុងប្រទេស** | **202,300,000** | **202,300,000** | **92,300,000** | **110,000,000** | **23,075,000** | **46%** |
| | | 61121 | សោហ៊ុយដឹកជញ្ជូន | 50,000,000 | 50,000,000 | 30,000,000 | 20,000,000 | 7,500,000 | 60% |
| | | 61122 | សោហ៊ុយបេសកកម្ម | 30,000,000 | 30,000,000 | 15,000,000 | 15,000,000 | 3,750,000 | 50% |
| | | 61123 | សោហ៊ុយស្នាក់នៅ | 122,300,000 | 122,300,000 | 47,300,000 | 75,000,000 | 11,825,000 | 39% |
| | 6113 | | **ចំណាយទូទាត់សោហ៊ុយក្រៅប្រទេស** | **35,100,000** | **35,100,000** | **12,000,000** | **23,100,000** | **3,000,000** | **34%** |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | 61131 | សោហ៊ុយដឹកជញ្ជូន | 20,000,000 | 20,000,000 | 5,000,000 | 15,000,000 | 1,250,000 | 25% |
| | | 61132 | សោហ៊ុយបេសកកម្ម | 11,000,000 | 11,000,000 | 5,000,000 | 6,000,000 | 1,250,000 | 45% |
| | | 61133 | សោហ៊ុយស្នាក់នៅ | 4,100,000 | 4,100,000 | 2,000,000 | 2,100,000 | 500,000 | 49% |
| | 6114 | | **សោហ៊ុយប្រៃសណីយ៍និងទូរគមនាគមន៍** | **20,000,000** | | | | | |
| | | 6115 | សោហ៊ុយទូរគមនាគមន៍ | 20,000,000 | | | | | |
| 64 | | | **បន្ទុកបុគ្គលិក** | **436,200,000** | **436,200,000** | **321,200,000** | **115,000,000** | **80,300,000** | 74% |
| | 6402 | | **លាភការនិងប្រាក់បំណាច់ បុគ្គលិកក្របខ័ណ្ឌអចិន្ត្រៃយ៍** | **315,400,000** | **315,400,000** | **215,400,000** | **100,000,000** | **53,850,000** | 68% |
| | | 64023 | ប្រាក់បំណាច់ម៉ោងបន្ថែម | 315,400,000 | 315,400,000 | 215,400,000 | 100,000,000 | 53,850,000 | 68% |
| | 6403 | | **ប្រាក់បំណាច់ផ្សេងៗ** | **74,000,000** | **74,000,000** | **69,000,000** | **5,000,000** | **17,250,000** | 93% |
| | | 64033 | រង្វាន់ | 64,000,000 | 64,000,000 | 64,000,000 | | 16,000,000 | 100% |
| | | 64037 | ប្រាក់ឧបត្ថម្ភក្រុមប្រឹក្សាភិបាលរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល | 10,000,000 | 10,000,000 | 5,000,000 | 5,000,000 | 1,250,000 | 50% |
| | 6405 | | **ប្រាក់វិភាជន៍សង្គមសម្រាប់មន្ត្រីរាជការ និងបុគ្គលិកផ្សេងៗ** | **46,800,000** | **46,800,000** | **36,800,000** | **10,000,000** | **9,200,000** | 79% |
| | | 64051 | មន្ត្រីមានជំងឺ | 10,000,000 | 10,000,000 | 10,000,000 | | 2,500,000 | 100% |
| | | 64052 | អ្នកសម្រាលកូន | 3,000,000 | 3,000,000 | 3,000,000 | | 750,000 | 100% |
| | | 64053 | មរណៈភាព | 6,000,000 | 6,000,000 | 6,000,000 | | 1,500,000 | 100% |
| | | 64054 | ឧបត្ថម្ភនិវត្តជន | 10,000,000 | 10,000,000 | 10,000,000 | | 2,500,000 | 100% |
| | | 64056 | គ្រោះថ្នាក់ក្នុងការងារ និងទព្វលភាព | 17,800,000 | 17,800,000 | 7,800,000 | 10,000,000 | 1,950,000 | 44% |
| 62 | | | **អត្ថប្រយោជន៍សង្គម** | **73,000,000** | **57,000,000** | **27,000,000** | **30,000,000** | **6,750,000** | 47% |
| | 6202 | | **ជំនួយសង្គមដល់ប្រជាពលរដ្ឋ** | **33,000,000** | **17,000,000** | **17,000,000** | | **4,250,000** | 100% |
| | | 62021 | ជំនួយដល់ប្រជាជនសំរាកពេទ្យនិងចំណាយដំណើរការ របស់មណ្ឌលថែទាំសុខភាព | 2,000,000 | 2,000,000 | 2,000,000 | | 500,000 | 100% |
| | | 62022 | ឱសថ | 5,000,000 | 5,000,000 | 5,000,000 | | 1,250,000 | 100% |
| | | 62023 | អាហារនិងសម្ភារៈ (ស្បៀង) | 8,000,000 | 8,000,000 | 8,000,000 | | 2,000,000 | 100% |
| | | 62025 | អាហាររូបករណ៍សម្រាប់ការសិក្សា- ស្រាវជ្រាវក្នុងប្រទេស | 10,000,000 | | | | | |
| | | 62026 | អាហាររូបករណ៍សម្រាប់ការសិក្សា- ស្រាវជ្រាវក្រៅប្រទេស | 6,000,000 | | | | | |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | 62028 | ជំនួយសង្គមផ្សេងៗទៀត | 2,000,000 | 2,000,000 | 2,000,000 | | 500,000 | 100% |
| | 6206 | | **ចំណាយអន្តរាគមន៍ផ្នែកសង្គមកិច្ចនិងវប្បធម៌** | **40,000,000** | **40,000,000** | **10,000,000** | **30,000,000** | **2,500,000** | **25%** |
| | | 62061 | ចំណាយលើការប្រឡង ប្រឡងប្រជែង | 40,000,000 | 40,000,000 | 10,000,000 | 30,000,000 | 2,500,000 | 25% |

ថ្ងៃ [illegible] ខែ [illegible] ឆ្នាំរកា នព្វស័ក ព.ស.២៥៦១
ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី[illegible] ខែ[illegible] ឆ្នាំ២០១៨
**រដ្ឋនេយ្យករបុរេប្រទាន**

បានឃើញ និងពិនិត្យត្រឹមត្រូវ
ថ្ងៃ [illegible] ខែ [illegible] ឆ្នាំរកា នព្វស័ក ព.ស.២៥៦១
ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី[illegible] ខែ[illegible] ឆ្នាំ២០១៨
**គណនេយ្យករ**
**ប្រចាំសាលាជាតិកសិកម្មព្រែកលៀប**

បានឃើញ និងពិនិត្យត្រឹមត្រូវ
ថ្ងៃ [illegible] ខែ [illegible] ឆ្នាំរកា នព្វស័ក ព.ស.២៥៦១
ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១៨
**ក. ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា**
**អគ្គនាយក នៃអគ្គនាយកដ្ឋានរតនាគារជាតិ**
**អគ្គនាយករង**

**ម៉ុញ បានសុវណ្ណអាទិច្ចាសីលា**

បានឃើញ និងឯកភាព
ថ្ងៃ [illegible] ខែ [illegible] ឆ្នាំរកា នព្វស័ក ព.ស.២៥៦១
ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី១០ ខែ[illegible] ឆ្នាំ២០១៨
**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**បណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

បានឃើញ និងឯកភាព
ថ្ងៃ [illegible] ខែ [illegible] ឆ្នាំរកា នព្វស័ក ព.ស.២៥៦១
ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី[illegible] ខែ[illegible] ឆ្នាំ២០១៨
**នាយក**
**សាលាជាតិកសិកម្មព្រែកលៀប**

**បណ្ឌិត ឆន់ វឌ្ឍនា**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ.៣៥០.....សហវ.ប្រក

# ប្រកាសអន្តរក្រសួង

## ស្តីពី

## ការតែងតាំងប្រធានបេឡាចំណូល និងអនុប្រធានបេឡាចំណូល ប្រចាំនៅអាជ្ញាធរជាតិអប្សរា នៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/ន.ស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខនស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៣/០០៤ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការធ្វើវិសោធនកម្មមាត្រា៩ និងមាត្រា១០ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា


ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៥ ស្តីពីលក្ខន្តិកៈគតិយុត្តិនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៧/០១៩ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៧ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៨
- បានឃើញអនុក្រឹត្យលេខ ១៣៩អនក្រ.បក ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការគ្រប់គ្រងថវិកានិងទ្រព្យសម្បត្តិរដ្ឋនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣១៧/៣១៣ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៧ ស្តីពីការផ្ទេរអាជ្ញាធរដើម្បីការពាររមណីយដ្ឋាន និងរៀបចំតំបន់អង្គរ ហៅថា "អប្សរា" ដែលត្រូវបានបង្កើតឡើងដោយព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥/១២ ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៩៥ ឱ្យស្ថិតនៅក្រោមសមត្ថកិច្ច និងការទទួលខុសត្រូវរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ។ រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈត្រូវទទួលបន្ទុកជាប្រធាននៃអាជ្ញាធរដើម្បីការពាររមណីយដ្ឋាន និងរៀបចំតំបន់អង្គរ ហៅថា "អប្សរា"។
- បានឃើញអនុក្រឹត្យលេខ ៥០អនក្រ.បក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់អគ្គនាយកដ្ឋាននៃអាជ្ញាធរអប្សរា
- បានឃើញអនុក្រឹត្យលេខ ៤៨៨អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៩អនក្រ.បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមាត្រា៤៤ មាត្រា៤៥ មាត្រា៤៦ និងមាត្រា៤៧ នៃអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៤អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ស្តីពីបទបញ្ញត្តិទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ០០៤សហវ.ម.ប្រក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការអនុវត្តបទបញ្ញត្តិទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ១២១២ សហវ.ប្រក ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តមាតិកាគណនីនៃប្លង់គណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ១៧១ សហវ.ប្រក ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីនីតិវិធីអនុវត្តថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញប្រកាសលេខ ១៧២ សហវ.ប្រក ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការប្រគល់សិទ្ធិជាអភិបាលហិរញ្ញវត្ថុជូនមន្ត្រីហិរញ្ញវត្ថុ ប្រចាំគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញប្រកាសលេខ ៥២៣ សហវ.ប្រក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ
- យោងតាមតម្រូវការចាំបាច់នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងអាជ្ញាធរជាតិអប្សរានៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

## សម្រេច

**ប្រការ១._**

ត្រូវបានតែងតាំងរជ្ជទេយ្យករចំណូលនិងរជ្ជទេយ្យករចំណូលរង របស់អាជ្ញាធរជាតិអប្សរានៃក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ដែលមានសមាសភាពដូចខាងក្រោម ÷

១-លោក **ឆុច បញ្ញាប្រាជ្ញា** ឋានៈមន្ត្រីនាយកដ្ឋានហិរញ្ញកិច្ច និងគណនេយ្យ ជារជ្ជទេយ្យករចំណូល

២-លោក **ខឹម ចិរៈ** ឋានៈបុគ្គលិកនាយកដ្ឋានហិរញ្ញកិច្ច និងគណនេយ្យ ជារជ្ជទេយ្យករចំណូលរង

**ប្រការ២._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៣._**

នាយកខុទ្ទកាល័យ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានរតនាគារជាតិ អាជ្ញាធរជាតិអប្សរា ប្រធានគ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ព្រមទាំងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃ ពុធ ១១ រោច ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១៨

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

បណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

**រដ្ឋមន្ត្រី**
**ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ**

ភឿង-សកុណា

**កន្លែងទទួល**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យ សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft

លេខ : ០១០៤ [illegible]

ថ្ងៃ [illegible] ខែ [illegible] ឆ្នាំរកា នព្វស័ក ព.ស.២៥៦១
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ [illegible] ឆ្នាំ២០១៨

# ប្រកាសបង្កើតរោងចក្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញសំណើសុំប្រកាសបង្កើតរោងចក្រផលិតខ្សែភ្លើងអគ្គិសនី និងអំពូលភ្លើងលំអ ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៧ របស់ក្រុមហ៊ុន សាន់រ៉ាយស៍ ឡៃថ៍ អេនធើប្រាយ ឯ.ក

## សម្រេច

**ប្រការ១៖** អនុញ្ញាតឱ្យក្រុមហ៊ុន សាន់រ៉ាយស៍ ឡៃថ៍ អេនធើប្រាយ ឯ.ក (SUNRISE LIGHT ENTERPRISE CO., LTD.) តំណាងដោយ លោក **WANG YANQIANG** បង្កើតរោងចក្រផលិតខ្សែភ្លើងអគ្គិសនី និងអំពូលភ្លើងលំអ ដែលមានទីតាំងស្ថិតនៅ តំបន់សេដ្ឋកិច្ចពិសេស មេនហាតធេនស្វាយរៀង (សង្កាត់បាវិត ក្រុងបាវិត ខេត្តស្វាយរៀង)។

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥)-២៣-២១១១៤១ , ទូរសារ : (៨៥៥)-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855-23-211141, Fax: 855-23-428263

| ឈ្មោះផលិតផល | លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code |
|---|---|
| ១. ខ្សែភ្លើងអគ្គិសនី | ២៧៣២ |
| ២. អំពូលភ្លើងលំអ | ២៧៤០ |

**ប្រការ២៖** ម្ចាស់រោងចក្រ ត្រូវលើកផ្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំស្តីពីការដាក់ឈ្មោះ រោងចក្រ និងសិប្បកម្ម។

**ផ្លាកឈ្មោះរោងចក្រ៖** " រោងចក្រផលិតខ្សែភ្លើងអគ្គិសនី និងអំពូលភ្លើងលំអ សាន់វ៉ាយស៍ ឡៃប៍ អេនធើប្រាយ ឯ.ក "

**ប្រការ៣៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងបទបញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

